ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរសវនកម្មជាតិ

រាយការណ៍សវនកម្ម
លើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ



លេខៈ ៣

ឆ្នាំ២០១៨

របាយការណ៍សវនកម្ម
លើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
ការិយបរិច្ឆេទ២០១២

អារម្ភកថា

នៅឆ្នាំ២០១២ កម្ពុជានៅតែរក្សាបាននូវសន្តិភាពពេញលេញទូទាំងប្រទេស រក្សាបានស្ថិរភាពនយោបាយ ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច កំណើនសេដ្ឋកិច្ចបន្តកើនឡើងខ្ពស់ បន្តនូវការអភិវឌ្ឍន៍យ៉ាងរឹងមាំ ជីវភាពប្រជាពលរដ្ឋមានភាពល្អប្រសើរ អត្រានៃភាពក្រីក្របន្តធ្លាក់ចុះ។ ប៉ុន្តែកម្ពុជានៅជួបបញ្ហាប្រឈមធំៗមួយចំនួនដែលត្រូវដោះស្រាយ។ ជាក់ស្តែង គ្រោះទឹកជំនន់ឆ្នាំ២០១១ បានបង្កផលប៉ះពាល់ធ្ងន់ធ្ងរដល់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដែលត្រូវស្តារឡើងវិញជាបន្ទាន់។ ជាមួយនេះផងដែរ ឆ្នាំ២០១២ គឺជាឆ្នាំនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងជាឆ្នាំដែលកម្ពុជាត្រូវទទួលធ្វើជាម្ចាស់ផ្ទះ ព្រមទាំងធ្វើជាប្រធាននៃកិច្ចប្រជុំកំពូលអាស៊ាន និងកិច្ចប្រជុំកំពូលពាក់ពន្ធផងដែរ ដែលកម្ពុជាបានបំពេញដោយជោគជ័យ និងកិត្យានុភាព។ ហេតុដូច្នេះហើយទាមទារឱ្យកម្ពុជាត្រូវចំណាយថវិកាយ៉ាងច្រើនសន្ធឹកសន្ធាប់សម្រាប់ដោះស្រាយនូវបញ្ហាប្រឈមទាំងនោះ។

ជាការពិតណាស់ ដោយភាពប៉ិនប្រសប់និងភាពឈ្លាសវៃរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលមាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជាប្រមុខ បានដោះស្រាយឆ្លងផុតបញ្ហាប្រឈម និងឧបសគ្គនានា ព្រមទាំងបានដឹកនាំនាវាកម្ពុជាប្រកបដោយសុខសន្តិភាព ស្ថិរភាពនយោបាយ រក្សាបានសន្តិសុខ របៀបរៀបរយ សណ្តាប់ធ្នាប់សង្គម និងការអភិវឌ្ឍន៍។ លើសពីនេះទៀត រាជរដ្ឋាភិបាលកម្ពុជាមានភាពប៉ិនប្រសប់ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ធ្វើឱ្យសម្រេចបានតាមការកំណត់ក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១២។ ជាក់ស្តែង ផ្លែផ្កានៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មានភាពល្អប្រសើរនេះ នាំមកនូវសេដ្ឋកិច្ចមានកំណើន ៧,៣% លើសពីការព្យាករណ៍ ដែលបានរំពឹងទុក ៦,៥% ។ ចំណូលមធ្យមសម្រាប់ប្រជាជនម្នាក់ៗនៅឆ្នាំ២០១២ បានកើនឡើងដល់ **៩៧៣** ដុល្លារអាមេរិក គឺបានកើនឡើង៦,៨% ធៀបទៅនឹងឆ្នាំ២០១១ រីឯអត្រានៃភាពក្រីក្រ បានធ្លាក់ចុះជាមធ្យមជាង ១% ក្នុង មួយឆ្នាំ។

ជាងនេះទៀត សមិទ្ធផលទាំងនេះ សបញ្ជាក់ឱ្យឃើញថា ពិតជាសក្តិសម និងត្រឹមត្រូវណាស់ ដែលរាជរដ្ឋាភិបាល បានប្រសិទ្ធនាមថវិកាឆ្នាំ២០១២ ថា ថវិកាសម្រាប់ **«បន្តពង្រឹងពង្រីកមូលដ្ឋានសេដ្ឋកិច្ច និងវឌ្ឍនភាពសង្គម តាមរយៈការបន្តរក្សាស្ថិរភាពនយោបាយ ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ស្ថិរភាពហិរញ្ញវត្ថុសាធារណៈ ការបន្តជំរុញការអភិវឌ្ឍន៍វិស័យគន្លឹះនានា ពិសេសវិស័យកសិកម្ម និងឧស្សាហកម្ម ក៏ដូចជាពង្រឹងនិងពង្រីកការអនុវត្តលិទ្ធិប្រជាធិបតេយ្យ និងអនុវត្តកម្មវិធីកំណែទម្រង់លើគ្រប់វិស័យឱ្យកាន់តែស៊ីជម្រៅ»**។

ក្នុងបរិបទនេះ អាជ្ញាធរសវនកម្មជាតិផ្សព្វផ្សាយរបាយការណ៍សវនកម្មជាសាធារណៈ ដោយអនុលោមតាមច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា។ របាយការណ៍នេះ លើកឡើងពីលទ្ធផលនៃការធ្វើសវនកម្មលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការអនុលោមតាមបទប្បញ្ញត្តិ និងកិច្ចប្រតិបត្តិការការងារក្នុងការិយបរិច្ឆេទ២០១២ របស់ក្រសួង-ស្ថាប័ន រដ្ឋបាលរាជធានី-ខេត្ត រដ្ឋបាលមូលដ្ឋាន សហគ្រាសសាធារណៈ និងអង្គភាពពាក់ព័ន្ធនានាមួយចំនួន ក្នុងគោលបំណងរួមចំណែកធ្វើឱ្យការប្រើប្រាស់ធនធានិងថវិកាសាធារណៈប្រកបដោយភាពត្រឹមត្រូវ និងមានប្រសិទ្ធភាព។

ក្នុងស្មារតីទទួលខុសត្រូវ និងការខិតខំប្រឹងប្រែងរបស់មន្ត្រីសវនកម្ម ព្រមទាំងមានការជួយឧបត្ថម្ភគាំទ្រពីគ្រប់មជ្ឈដ្ឋានទាំងផ្នែកស្មារតី និងសម្ភារៈ បានជំរុញឲ្យអាជ្ញាធរសវនកម្មជាតិមានសក្តានុពលក្នុងការអនុវត្តការងារសម្រេចបានតាមផែនការយុទ្ធសាស្ត្រ (២០០៧-២០១១) និងកំពុងបន្តផែនការយុទ្ធសាស្ត្រ (២០១២-២០១៦)របស់ខ្លួន។ ចំពោះមុខអាជ្ញាធរសវនកម្មជាតិនឹងខិតខំបន្ថែមទៀត ដោយធ្វើការពង្រីកវិសាលភាពសវនកម្ម ពង្រឹងសមត្ថភាពមន្ត្រី និងបង្កើនគុណភាពសវនកម្ម ដើម្បីឈានទៅសម្រេចបានទស្សនៈដារសវនកម្មជាតិនិងអន្តរជាតិ ព្រមទាំងឆ្លើយតបទៅនឹងតម្រូវការរបស់ប្រទេសជាតិ។

ក្នុងនាមអាជ្ញាធរសវនកម្មជាតិ ក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមថ្លែងអំណរគុណ និងដឹងគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះរាជរដ្ឋាភិបាល រដ្ឋសភា ព្រឹទ្ធសភា ដែលជានិច្ចកាលតែងតែគាំទ្រអាជ្ញាធរសវនកម្មជាតិទាំងក្នុងក្របខណ្ឌច្បាប់ ក៏ដូចជាក្របខណ្ឌហិរញ្ញវត្ថុ សម្ភារៈ និងស្មារតី។ ជាមួយគ្នានេះដែរ ខ្ញុំសូមអរគុណផងដែរដល់អង្គការកិច្ចសហប្រតិបត្តិការអន្តរជាតិរបស់សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ (GIZ) ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ព្រមទាំងដៃគូអភិវឌ្ឍន៍ និងស្ថាប័នសវនកម្មកំពូលនានា ដែលបានផ្តល់ការគាំទ្រ និងឧបត្ថម្ភផ្សេងៗក្នុងកិច្ចដំណើរការអភិវឌ្ឍស្ថាប័ន។ ម្យ៉ាងវិញទៀត ខ្ញុំសូមអរគុណ និងកោតសរសើរចំពោះថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃអាជ្ញាធរសវនកម្មជាតិទាំងអស់ដែលបានខិតខំប្រឹងប្រែងលះបង់ពុះពារការលំបាក ឧបសគ្គនានា បំពេញភារកិច្ចធ្វើឲ្យសម្រេចបាននូវលទ្ធផលគួរជាទីមោទនៈ។ ឆ្លៀតក្នុងឱកាសនេះដែរ ខ្ញុំសូមថ្លែងអំណរគុណដល់អង្គភាពរងសវនកម្ម និងសាធារណជន ទាំងឡាយដែលបានសហការ និងលើកទឹកចិត្តចំពោះរាល់ការងារបម្រើឲ្យវិស័យសវនកម្មសាធារណៈ នាពេលកន្លងមក។ អាជ្ញាធរសវនកម្មជាតិមានសង្ឃឹមយ៉ាងមុតមាំថា សកម្មភាពទាំងនេះនឹងនៅតែបន្តយ៉ាងសកម្ម ដែលបង្ហាញពីការចូលរួមចំណែកក្នុងការលើកស្ទួយ និងការអភិវឌ្ឍន៍ប្រទេសជាតិ។

រាជធានីភ្នំពេញ, ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៥

អគ្គសវនករ

សោម គីមសួគ៌

មាតិកា

សេចក្តីសង្ខេប ១

១. សេចក្តីផ្តើម ៣

១.១.លក្ខណៈទូទៅ ៣

១.២. ការអនុវត្ត និងដែនកំណត់សវនកម្ម ៣

១.៣. គោលបំណងនៃការផ្សព្វផ្សាយ ៤

២. ការគ្រប់គ្រងឋវិកា ៤

២.១.មូលដ្ឋានគតិយុត្តនៃការអនុវត្តឋវិកា ៤

២.២.កិច្ចប្រតិបត្តិការឋវិកា ៥

៣. លទ្ធផលសវនកម្ម ៦

៣.១.ការគ្រប់គ្រងឋវិកាថ្នាក់ជាតិ ៦

៣.១.១. ការមកបំពេញកាតព្វកិច្ចសារពើពន្ធរបស់ក្រុមហ៊ុន សហគ្រាសមួយចំនួន ៦

៣.១.២. ការប្រមូលពន្ធលើស្លាកយីហោ ៦

៣.១.៣. គុណភាពសវនកម្មតាមប្រភេទពន្ធ ៧

៣.១.៤. ការអនុវត្តតួនាទីរបស់សាខាគយ និងរដ្ឋាករាជធានីភ្នំពេញ ៧

៣.១.៥. ការកំណត់ទម្ងន់សម្រាប់គិតពន្ធលើទំនិញល្មើស ៨

៣.១.៦. ការបោះពុម្ពវិញ្ញាបនបត្រពិនិត្យសុខភាពកម្មករនិយោជិកខ្មែរនិងបរទេស..... ៩

៣.១.៧. ការតាមដានថវិកាចំណាយរដ្ឋទេយ្យបុរេប្រទានតាមកម្មវិធី ៩

៣.១.៨.ការប្រមូលផ្តុំកិច្ចលទ្ធកម្មដាក់ជាកញ្ចប់លទ្ធកម្ម..... .១០

៣.១.៩.ការបើកឯកសារនិងប្រគល់កិច្ចសន្យាលទ្ធកម្ម ១០

៣.១.១០.ការប្រមូលចំណូលពីអាជ្ញាបណ្ណប្រេកង់ស៍ ១១

៣.១.១១.ការចេញសារណាការទារចំណូលលើផ្នែក Regulator fee ពីក្រុមហ៊ុន ១១

៣.១.១២.ការចុះកិច្ចសន្យាស្តីពីការបង់ចំណូលដុលជាមួយក្រុមហ៊ុនចម្រុះ..... ១២

៣.២. ការគ្រប់គ្រងឋវិការដ្ឋបាលថ្នាក់ក្រោមជាតិ..... ១២

៣.២.១.ការស្វែងរកមុខសញ្ញាចំណូល ១២

៣.២.២.ការប្រមូលចំណូលសោហ៊ុយសេវាលើការបិទការដ្ឋានសំណង់.....១៣

៣.៣.ការអនុវត្តគម្រោងវិនិយោគ ១៤

៣.៣.១. ការបង្កើតគណៈកម្មការទទួលខុសត្រូវក្នុងការត្រួតពិនិត្យតាមដានលើ
ការអនុវត្តកិច្ចសន្យាវិនិយោគ ១៤

៣.៣.២.ការយកតម្លៃភាស៊ីគ្រប់ប្រភេទ ១៥

៤.ការពិនិត្យទៅលើវឌ្ឍនភាពនៃការអនុវត្តអនុសាសន៍សវនកម្ម..... ១៥

៥.សេចក្តីសន្និដ្ឋាន ២២

របាយការណ៍សវនកម្ម
លើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈសម្រាប់ការិយបរិច្ឆេទ២០១២

សេចក្តីសង្ខេប

អាជ្ញាធរសវនកម្មជាតិ ជាស្ថាប័នសាធារណៈដែលឯករាជ្យអំពីកិច្ចប្រតិបត្តិការនៃការងារ និងមានភារកិច្ចចំពោះការអនុវត្តមុខងារសវនកម្មផ្នែកក្រៅរបស់រាជរដ្ឋាភិបាល។ ស្ថាប័ននេះត្រូវបានបង្កើតឡើងដោយច្បាប់ស្តីពីសវនកម្ម នៃព្រះរាជាណាចក្រកម្ពុជាដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០។ អនុលោមតាមមាត្រា២ មាត្រា៣ មាត្រា២៩ និងមាត្រា៣៧នៃច្បាប់នេះ អាជ្ញាធរសវនកម្មជាតិមានកាតព្វកិច្ចធ្វើសវនកម្ម និងផ្សព្វផ្សាយលទ្ធផលសវនកម្មដែលចាំបាច់។

ពិនិត្យជារួម ទោះបីកម្ពុជាបានជួបប្រទះនូវគ្រោះទឹកជំនន់ ស្ថានភាពសេដ្ឋកិច្ចនៅមានលក្ខណៈជុំយស្រួយ និងមានហានិភ័យខ្ពស់យ៉ាងណាក្តី ក៏រាជរដ្ឋាភិបាលកម្ពុជានៅតែរក្សាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងកំណើនសេដ្ឋកិច្ច៧.៣% លើសពីការព្យាករណ៍ ដែលបានរំពឹងទុក ៦.៥% ព្រមទាំងកាត់បន្ថយបាននូវភាពក្រីក្រជាង១% ក្នុងមួយឆ្នាំ ដែលជាលទ្ធផលគួរឲ្យកត់សម្គាល់។

សម្រាប់ការិយបរិច្ឆេទ២០១២ អាជ្ញាធរសវនកម្មជាតិបានធ្វើសវនកម្មលើបណ្តាក្រសួង-ស្ថាប័នរដ្ឋបាលរាជធានី-ខេត្ត រដ្ឋបាលមូលដ្ឋាន សហគ្រាសសាធារណៈ គម្រោងផ្សេងៗ និងសម្បទានវិនិយោគមួយចំនួនដែលមានលទ្ធផលសង្ខេបខាងក្រោម៖

ក. កិច្ចប្រតិបត្តិការថវិកាថ្នាក់ជាតិ

ការអនុវត្តចំណូលតាមរយៈរតនាគារជាតិសម្រេចបានចំនួន ៨.២៦១.៦៥២,១លានរៀល ស្មើនឹង១០៤,៦%នៃច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំដែលមានចំនួន៧.៩០០.៦៥៧,០លានរៀល។ ទន្ទឹមនឹងលទ្ធផលដែលសម្រេចបាននេះ បើផ្អែកតាមលទ្ធផលនៃការធ្វើសវនកម្មបានបង្ហាញឲ្យឃើញថា ចំណូលនេះនៅមិនអស់សក្តានុពលនៅឡើយ ដែលមានជាអាទិ៍៖ ការមកបំពេញកាតព្វកិច្ចសារពើពន្ធរបស់ក្រុមហ៊ុនសហគ្រាសមួយចំនួន ការប្រមូលពន្ធលើស្លាកយីហោ គុណភាពសវនកម្មតាមប្រភេទពន្ធ ការអនុវត្តតួនាទីរបស់សាខាគយ និងរដ្ឋាករាជធានីភ្នំពេញ ការកំណត់ទម្ងន់សម្រាប់គិតពន្ធលើទំនិញឡើស ការបោះពុម្ពវិញ្ញាបនបត្រពិនិត្យសុខភាពកម្មករនិយោជិកខ្មែរនិងបរទេស ការប្រមូលចំណូលពីអាជ្ញាបណ្ណប្រេកង់ស៍ ការចេញសារណាការទារចំណូលលើផ្នែក Regulator fee ពីក្រុមហ៊ុន ការចុះកិច្ចសន្យាស្តីពីការបង់ចំណូលដុលជាមួយក្រុមហ៊ុនចម្រុះ ការប្រើប្រាស់ឬការចេញវិក្កយបត្រឲ្យទៅអតិថិជន របាយការណ៍សវនកម្មរបស់សវនករឯករាជ្យ ការផ្តល់អាជ្ញាប័ណ្ណអាជីវកម្មទទួលបញ្ចាំនិងទិញ-លក់ទ្រព្យបញ្ចាំ ការទៅបំពេញកាតព្វកិច្ចចុះបញ្ជីសារពើពន្ធសហគ្រាស ការប្រកាសពន្ធរបស់សហគ្រាស ការបញ្ចូលមូលដ្ឋានអាជីវកម្មទៅក្នុងរបបស្វ័យប្រកាស ភាពសហការរវាងអគ្គនាយកដ្ឋានពន្ធដារ និង

អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ការជម្រះផ្ទេរចំណូលចូលថវិកា ការតាមដានលើការប្រើប្រាស់ទំនិញនាំចូលក្រោមរបបអនុគ្រោះពន្ធ ការដោះស្រាយទំនិញគ្មានការទាមទារ ការរក្សាទុកប្រាក់លក់ទំនិញរឹបអូសនិងទំនិញបាតឃ្លាំងការរក្សាទុកសាច់ប្រាក់ក្នុងបេឡាលើសកម្រិតកំណត់ ការកត់ត្រាចំណូលថវិការដ្ឋ និងការបន្សល់ទុកនូវបំណុលត្រូវទារជាច្រើន...។

ការអនុវត្តចំណាយតាមរយៈរតនាគារជាតិសម្រេចបានចំនួន៨.០៧៥.៦៣៣,១ លានរៀល ស្មើនឹង១០០,៨% នៃច្បាប់ស្តីពីហិរញ្ញវត្ថុដើមឆ្នាំដែលមានចំនួន៨.០១២.៩៨២,០លានរៀល។ នៅក្នុងការអនុវត្តចំណាយថវិកានេះមានចំណុចគួរខិតខំធ្វើឱ្យបានប្រសើរឡើងថែមទៀត មានជាអាទិ៍៖ ការតាមដានថវិកាចំណាយរដ្ឋទេយ្យបុរេប្រទានតាមកម្មវិធី ការប្រមូលផ្តុំកិច្ចលទ្ធកម្មដាក់ជាកញ្ចប់លទ្ធកម្ម ការបើកឯកសារនិងប្រគល់កិច្ចសន្យាលទ្ធកម្ម ការបង្កើតគណៈកម្មការទទួលខុសត្រូវក្នុងការត្រួតពិនិត្យតាមដានលើការអនុវត្តកិច្ចសន្យាវិនិយោគ ការធ្វើផែនការនិងការធ្វើផែនការលទ្ធកម្មប្រចាំឆ្នាំ ការទូទាត់និងការកត់ត្រាចំណាយ ការទូទាត់ប្រាក់បុរេប្រទាន ការដកចំណូលយកទៅចំណាយការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ ការបើកផ្តល់ និងការទូទាត់ និងការកត់ត្រាចំណាយតាមគោលការណ៍ហិរញ្ញវត្ថុ។

កិច្ចប្រតិបត្តិការថវិកាអនុវត្តក្រៅរតនាគារជាតិត្រូវបានគ្រោងទុកដោយមានតុល្យភាពចំណូលសរុបស្មើនឹងចំណាយសរុប។ កិច្ចប្រតិបត្តិការនេះសម្រេចបានចំនួន៤.០២២.៦៣៤,៥លានរៀល ស្មើនឹង ១៤០,៧% នៃច្បាប់ហិរញ្ញវត្ថុដែលមានចំនួន២.៨៦០.០០០,០លានរៀល។ បញ្ហាកត់សម្គាល់គឺតួលេខវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសជាអំណោយមានចំនួន១.៥៥៥.៨០៧,៤លានរៀល ពុំមានឯកសារគ្រប់គ្រាន់សម្រាប់ធ្វើសវនកម្មឡើយ។

ខ. កិច្ចប្រតិបត្តិការថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

ការអនុវត្តចំណូលសម្រេចបានចំនួន៧៦២.៣៣៨,០លានរៀល ស្មើនឹង១៧៨,២% នៃច្បាប់ហិរញ្ញវត្ថុដែលមានចំនួន៤២៧.៨៣០,០លានរៀល។ រីឯការអនុវត្តចំណាយសម្រេចបានចំនួន ៥៧៨.១២១,០លានរៀល ស្មើនឹង១៣៥.១% នៃច្បាប់ហិរញ្ញវត្ថុដែលមានចំនួន៤២៧.៨៣០,០លានរៀល គឺមានអតិរេកសរុបចំនួន១៨៥.២១៧,០លានរៀល។ ផ្អែកតាមលទ្ធផលនៃការធ្វើសវនកម្ម បានបង្ហាញឱ្យឃើញថា ការស្វែងរកមុខសញ្ញាចំណូល ការប្រមូលចំណូលសោហ៊ុយសេវាលើការបិទការដ្ឋានសំណង់ ការយកតម្លៃភាស៊ីគ្រប់ប្រភេទ ការប្រមូលពន្ធលើអចលនទ្រព្យ ការគ្រប់គ្រងអ្នកជាប់ពន្ធតាមរបបមៅការ ការប្រមូលពន្ធតាមរបបមៅការ និងការបន្សល់ទុកនូវបំណុលពន្ធត្រូវទារកើនពីមួយឆ្នាំទៅមួយឆ្នាំដែលគួរត្រូវខិតខំធ្វើឱ្យប្រសើរឡើងថែមទៀត។

គ. ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ

ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនៅមានបញ្ហាកត់សម្គាល់ គឺរហូតមកដល់បច្ចុប្បន្នមានក្រសួង-ស្ថាប័ន និងសាលារាជធានី-ខេត្តមួយចំនួន ដែលនៅតែមានភាពយឺតយ៉ាវ និងខកខានក្នុងការធ្វើបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ និងប័ណ្ណសម្គាល់កម្មសិទ្ធិលើទ្រព្យសម្បត្តិ ទោះបីជាក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុធ្លាប់បានចេញប្រកាស និងសារាចរណែនាំក្រើនរំលឹកជាញឹកញាប់យ៉ាងណាក៏ដោយ។

១. សេចក្តីផ្តើម

១.១. លក្ខណៈទូទៅ

ច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជាតម្រូវឲ្យអាជ្ញាធរសវនកម្មជាតិមានភារកិច្ច អនុវត្តមុខងារសវនកម្មផ្នែកក្រៅរបស់រាជរដ្ឋាភិបាល ក្នុងនោះ រួមមានការធ្វើសវនកម្មលើកិច្ចបញ្ជិកា គណនេយ្យ គណនី ប្រព័ន្ធគ្រប់គ្រង ការត្រួតពិនិត្យកិច្ចប្រតិបត្តិការ និងកម្មវិធីរបស់បណ្តាក្រសួង ស្ថាប័ន ភ្នាក់ងារ អាជ្ញាធរ ធនាគារជាតិ ស្ថាប័នហិរញ្ញវត្ថុរដ្ឋ និងស្ថាប័នហិរញ្ញវត្ថុចម្រុះឯកជន សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈ រដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលមូលដ្ឋាន អ្នកមៅការ អ្នកផ្គត់ផ្គង់ទំនិញ និងសេវាកម្មចំពោះរាជរដ្ឋាភិបាលតាមកិច្ចសន្យា និងបណ្តាអង្គការផ្សេងៗ ទៀតដែលរាជរដ្ឋាភិបាលបានផ្តល់ជំនួយហិរញ្ញវត្ថុបន្ថែមលើទុនផ្ទាល់ និងឥណទាន រួមមានទាំង ការលើកលែងពន្ធអាករគ្រប់ប្រភេទ ព្រមទាំងសម្បទានផ្សេងៗទៀតទៅអង្គការដែលមិនរកប្រាក់ចំណេញ និងសហគ្រាសវិនិយោគឯកជន...។

ជាមួយនេះផងដែរ អាជ្ញាធរសវនកម្មជាតិមានភារកិច្ចធ្វើសវនកម្មបញ្ជាក់លើសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំនីមួយៗ ហើយត្រូវធ្វើរបាយការណ៍សវនកម្មជូនទៅរដ្ឋសភា ព្រឹទ្ធសភាដោយផ្ទាល់ និងជូនទៅរាជរដ្ឋាភិបាល ដើម្បីជ្រាបជាព័ត៌មាន ព្រមទាំងធ្វើការផ្សព្វផ្សាយនូវលទ្ធផលសវនកម្មដែលចាំបាច់។

១.២. ការអនុវត្តនិងដែនកំណត់សវនកម្ម

ចាប់តាំងពីអាជ្ញាធរសវនកម្មជាតិបានដំណើរការការងារនៅចុងឆ្នាំ២០០១ រហូតមកដល់ឆ្នាំ២០១២ អាជ្ញាធរសវនកម្មជាតិបានអនុវត្តភារកិច្ចធ្វើសវនកម្មនៅតាមបណ្តាក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី-ខេត្ត រដ្ឋបាលមូលដ្ឋាន សហគ្រាសសាធារណៈ គម្រោង និងសម្បទានវិនិយោគ ផ្សេងៗសរុបមានចំនួន៥៩៨របាយការណ៍ ជាពិសេសគឺការធ្វើសវនកម្មបញ្ជាក់លើសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំនីមួយៗ។ ដោយឡែកសម្រាប់ការិយបរិច្ឆេទ២០១២ អាជ្ញាធរសវនកម្មជាតិបានធ្វើសវនកម្ម និងរៀបចំរបាយការណ៍សរុបមានចំនួន៤៤របាយការណ៍ ដែលខ្លឹមសារសំខាន់ៗមួយចំនួនក្នុងរបាយការណ៍ត្រូវបានដកស្រង់មកបង្ហាញក្នុងចំណុចទី៣ នៃរបាយការណ៍សម្រាប់ផ្សព្វផ្សាយជាសាធារណៈនេះ។

អាជ្ញាធរសវនកម្មជាតិធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារសវនកម្មសាធារណៈ នៃព្រះរាជាណាចក្រកម្ពុជា ដែលតម្រូវឲ្យមានការរៀបចំផែនការនិងអនុវត្តការងារសវនកម្មដោយផ្អែកលើមូលដ្ឋាននៃការត្រួតពិនិត្យវាយតម្លៃលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការអនុលោមតាមបទប្បញ្ញត្តិ និងកិច្ចប្រតិបត្តិការការងាររបស់ក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធនានា ព្រមទាំងការធ្វើតេស្តលើឯកសារផ្សេងៗដើម្បីទទួលបានភស្តុតាងសវនកម្មសមស្របសម្រាប់ការធ្វើសេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍កែលម្អដល់អង្គភាពរងសវនកម្មទាំងនោះ។

១.៣. គោលបំណងនៃការផ្សព្វផ្សាយ

ការផ្សព្វផ្សាយរបាយការណ៍សវនកម្មជាសាធារណៈ មានគោលបំណងចូលរួមចំណែកជាមួយស្ថាប័ននីតិប្បញ្ញត្តិ និងនីតិប្រតិបត្តិ ក្នុងការពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកិច្ចប្រតិបត្តិការការងាររបស់ក្រសួង-ស្ថាប័ន រដ្ឋបាលរាជធានី-ខេត្ត រដ្ឋបាលមូលដ្ឋាន និងអង្គភាពពាក់ព័ន្ធនានា តាមរយៈការចង្អុលបង្ហាញនូវចំណុចខ្វះខាតក្នុងការអនុវត្តកន្លងមក និងផ្តល់អនុសាសន៍កែលម្អលើចំណុចខ្វះខាតទាំងនោះ សំដៅធ្វើឲ្យមានភាពកាន់តែប្រសើរ ក្នុងការគ្រប់គ្រងធនធាន និងក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

អាជ្ញាធរសវនកម្មជាតិ អនុវត្តកាតព្វកិច្ចផ្សព្វផ្សាយរបាយការណ៍សវនកម្មជាសាធារណៈ ដោយអនុលោមតាមមាត្រា២៩ នៃច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ដែលបានចែងថា របាយការណ៍ដែលធ្វើដោយអគ្គសវនករត្រូវបានចាត់ទុកជាឯកសារសាធារណៈ។ អាជ្ញាធរសវនកម្មជាតិមិនទទួលខុសត្រូវអំពីផលប៉ះពាល់ណាមួយចំពោះក្រសួង-ស្ថាប័ន រដ្ឋបាលរាជធានី-ខេត្ត រដ្ឋបាលមូលដ្ឋាន ក្រុមហ៊ុន-សហគ្រាស ឬបុគ្គលពាក់ព័ន្ធនានា ក្នុងពេលដែលមានតតីយជនទាំងឡាយណាយកខ្លឹមសារក្នុងរបាយការណ៍ផ្សព្វផ្សាយជាសាធារណៈនេះទៅធ្វើការបកស្រាយឬប្រើប្រាស់ខុសគោលដៅ។

២. ការគ្រប់គ្រងថវិកា

២.១. មូលដ្ឋានគតិយុត្តនៃការអនុវត្តថវិកា

កិច្ចដំណើរការនៃថវិកាឆ្នាំ២០១២នេះ ត្រូវបានប្រព្រឹត្តទៅដោយផ្អែកលើមូលដ្ឋានច្បាប់ និងលិខិតបទដ្ឋានគតិយុត្តមួយចំនួន ដែលមានជាអាទិ៍ ៖

- ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ប្រកាសឲ្យប្រើដោយព្រះរាជក្រម លេខនស/រកម/ ០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨
- ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១២ ប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/ ១២១១/០១៩ ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១១
- ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ ប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/ ១២១២/០១០ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១២ ជំពូកទី៤ ស្តីពីនិយ័តភាវូបនីយកម្មនៃកិច្ចប្រតិបត្តិការចំណាយថវិកាបន្ថែមសម្រាប់ការគ្រប់គ្រងឆ្នាំ២០១២
- ច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១
- អនុក្រឹត្យលេខ៨២អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- អនុក្រឹត្យលេខ០៤អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

២.២. កិច្ចប្រតិបត្តិការថវិកា

កិច្ចប្រតិបត្តិការថវិកាឆ្នាំ២០១២ ត្រូវបានរៀបចំឡើងដោយផ្អែកតាមលទ្ធផលនៃការអនុវត្តចំណូល-ចំណាយ តាមរយៈរតនាគារជាតិ រតនាគាររាជធានី-ខេត្ត និងលទ្ធផលនៃការអនុវត្តគម្រោងវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសដែលអនុវត្តក្រៅរតនាគារជាតិ ដូចមានបង្ហាញក្នុងតារាងខាងក្រោម ៖

ក. កិច្ចប្រតិបត្តិការថវិកាថ្នាក់ជាតិ

ឯកតា : លានរៀល

បរិយាយ	អនុវត្ត ២០១១	២០១២		
		ច្បាប់ហិរញ្ញវត្ថុ	អនុវត្ត	ភាគរយ
	1	*2*	*3*	*4 = (3/2)*
I. សរុបចំណូល	**10.071.358,8**	**10.767.982,0**	**12.284.286,6**	**114,1%**
-ចំណូលចរន្ត	6.370.103,2	7.300.657,0	7.892.679,9	108,1%
-ចំណូលមូលធនក្នុងប្រទេស	76.544,3	80.000,0	250.851,7	313,6%
-មូលនិធិទ្រទ្រង់ថវិកា	222.019,5	520.000,0	118.120,5	22,7%
-ប្រើប្រាស់ប្រាក់បញ្ញើរាជរដ្ឋាភិបាល	-	7.325,0	-	-
-ចំណូលមូលធនដោយហិរញ្ញប្បទានក្រៅប្រទេស	3.402.691,8	2.860.000,0	4.022.634,5	140,7%
II. សរុបចំណាយ	**10.694.383,6**	**10.872.982,0**	**12.097.267,6**	**111,3%**
-ចំណាយចរន្ត	5.784.314,7	6.435.657,0	6.677.327,3	103,8%
-ចំណាយមូលធន	1.507.377,1	1.577.325,0	1.397.305,8	88,6%
-ចំណាយមូលធនដោយហិរញ្ញប្បទានក្រៅប្រទេស	3.402.691,8	2.860.000,0	4.022.634,5	140,7%

ខ. កិច្ចប្រតិបត្តិការថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

ឯកតា : លានរៀល

បរិយាយ	អនុវត្ត ២០១១	២០១២		
		ច្បាប់ហិរញ្ញវត្ថុ	អនុវត្ត	ភាគរយ
	1	*2*	*3*	*4 = (3/2)*
I. សរុបចំណូល	**634.954**	**427.830,0**	**762.338,0**	**178,2%**
-ចំណូលចរន្ត	410.522	332.154,0	492.692,0	148,3%
•ចំណូលសារពើពន្ធ	384.861	310.189,0	465.242,5	150,0%
•ចំណូលមិនមែនសារពើពន្ធ	25.661	21.965,0	27.449,5	125,0%
-ឧបត្ថម្ភពីថវិកាថ្នាក់ជាតិ	224.432	95.676,0	269.646,0	281,8%
II. សរុបចំណាយ	**472.984**	**427.830,0**	**578.121,0**	**135,1%**
-ចំណាយចរន្ត	364.059	342.812,0	450.237,7	131,3%
-ចំណាយមូលធន	108.925	85.018,0	127.883,3	150,4%

៣.លទ្ធផលសវនកម្ម

៣.១. ការគ្រប់គ្រងថវិកាជាតិ

៣.១.១.ការមកបំពេញកាតព្វកិច្ចសារពើពន្ធរបស់ក្រុមហ៊ុន សហគ្រាសមួយចំនួន

ដើម្បីគ្រប់គ្រងការប្រមូលចំណូលសារពើពន្ធ រដ្ឋបាលសារពើពន្ធតម្រូវឱ្យអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកដាក់លិខិតប្រកាសសារពើពន្ធទៅតាមទម្រង់ពេលវេលា និងទីកន្លែង ដែលរដ្ឋបាលសារពើពន្ធបានកំណត់ ឬទីកន្លែងដែលអ្នកជាប់ពន្ធចុះបញ្ជីសារពើពន្ធ។ ករណីដែលបុគ្គលមិនបានដាក់លិខិតប្រកាសសារពើពន្ធក្នុងរយៈពេល៣០ថ្ងៃក្រោយកាលបរិច្ឆេទ ដែលច្បាប់កំណត់ បុគ្គលនោះនឹងរងនូវការពិន័យអំពើអំពើរាំងស្ទះការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ។ ជាងនេះទៅទៀត ក្រៅពីទោសទណ្ឌផ្នែករដ្ឋបាលផ្សេងទៀត បុគ្គលណាមួយបានធ្វើសកម្មភាពគេចវេះពន្ធ ឬធ្វើការរាំងស្ទះដល់ការគ្រប់គ្រងប្រមូលចំណូលសារពើពន្ធត្រូវបានចាត់ទុកថា បានប្រព្រឹត្តបទល្មើសផ្នែកព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ។ តាមការពិនិត្យបញ្ជីឈ្មោះក្រុមហ៊ុនដែលបានចុះបញ្ជីក្នុងឆ្នាំ២០១២ នៅនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ សាខាពន្ធដារខណ្ឌ និងសាខាពន្ធដារខេត្តមួយចំនួន និងលិខិតជូនដំណឹងរបស់រដ្ឋបាលសារពើពន្ធចំពោះលោក លោកស្រី នាយកក្រុមហ៊ុននីមួយៗឲ្យមកដាក់លិខិតប្រកាសពន្ធ និងបង់ប្រាក់ពន្ធប្រចាំខែ និងប្រចាំឆ្នាំ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រុមហ៊ុនចំនួន៧៩៥ ក្នុងចំណោម២.៨៨៧ ក្រុមហ៊ុន មិនបានមកដាក់លិខិតប្រកាសពន្ធប្រចាំខែ និងប្រចាំឆ្នាំ២០១២ទេ។

ដោយសារតែរដ្ឋបាលសារពើពន្ធគ្រាន់តែបានធ្វើលិខិតរំលឹកដល់ក្រុមហ៊ុនឱ្យមកដាក់លិខិតប្រកាស ហើយមិនបានបន្តអនុវត្តវិធានការបន្ថែមទៀត ទើបធ្វើឱ្យអ្នកជាប់ពន្ធទាំងអស់នោះ មិនយកចិត្តទុកដាក់ចំពោះការបំពេញកាតព្វកិច្ចសារពើពន្ធឱ្យបានពេញលេញ។

ឆ្លើយតបនឹងបញ្ហាខាងលើ អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានអនុវត្តវិធានការ ដូចជាចុះពន្យល់ណែនាំ ចុះស្រាវជ្រាវរកទីតាំងអាសយដ្ឋានរបស់សហគ្រាសដែលបានចុះបញ្ជីរួច ធ្វើការណែនាំឱ្យធ្វើលិខិតរំលឹកដល់សហគ្រាស ចេញលិខិតរំលឹកពីការដកហូតវិញ្ញាបនប័ត្រចុះបញ្ជីអាករលើតម្លៃបន្ថែមចំពោះសហគ្រាសនាំចេញ-នាំចូលដែលខកខានមិនបានបំពេញកាតព្វកិច្ច៣ខែជាប់គ្នា។ ជាងនេះទៅទៀត អគ្គនាយកដ្ឋានពន្ធដារគ្រោងបន្តធ្វើការលុបចេញពីបញ្ជី (De-registration) ចំពោះសហគ្រាសដែលបានបាត់ខ្លួន ព្រមទាំងត្រៀមដាក់ឱ្យដំណើរការសាកល្បងប្រព័ន្ធជូនដំណឹងជាស្វ័យប្រវត្តិ (Notification System) ទៅក្នុងអ៊ីមែល និងទូរស័ព្ទដៃរបស់អ្នកជាប់ពន្ធ។

៣.១.២. ការប្រមូលពន្ធលើស្លាកយីហោ

បណ្ណប្រកាសផ្សាយពាណិជ្ជកម្ម ស្លាកអាជីវកម្មដ្ឋាន ផ្ទាំងអក្សរ និងផ្ទាំងរូបភាពលើកក្នុងគោលបំណងផ្សាយពាណិជ្ជកម្មនឹងត្រូវជាប់ពន្ធតាមទំហំ និងតាមផ្ទៃក្រឡា ដូចជា (ក).បណ្ណប្រកាសផ្សាយពាណិជ្ជកម្មធ្វើដោយក្រដាសធម្មតា (ខ).បណ្ណប្រកាសផ្សាយពាណិជ្ជកម្មធ្វើដោយក្រណាត់ ឬវត្ថុធាតុផ្សេងៗ (គ).ស្លាកអាជីវកម្មដ្ឋាននានា (ឃ).ផ្ទាំងអក្សរផ្ទាំងរូបភាពលើកក្នុងគោលបំណងផ្សាយពាណិជ្ជកម្ម។ តាមការធ្វើសវនកម្មលើបញ្ជីពន្ធស្លាកអាជីវកម្មប្រចាំ

ឆ្នាំ២០១២ និងតាមការធ្វើតេស្តលើការប្រមូលពន្ធលើស្លាកអាជីវកម្មនៅសាខាពន្ធដារខណ្ឌនៃរាជធានីភ្នំពេញ និងសាខាពន្ធដារខេត្តចំនួន៩ ក្នុងចំណោមសាខាពន្ធដាររាជធានី ខេត្តចំនួន ២៤ ដោយជ្រើសរើសស្លាកអាជីវកម្មចំនួនតែ១.៥៣៧ ពីបញ្ជីពន្ធមកធ្វើការប្រៀបធៀបជាមួយនឹងការរាប់ស្លាកអាជីវកម្ម អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ស្លាកអាជីវកម្មរាប់ជាក់ស្តែងមានចំនួន១.៨២៥ គឺនៅសេសសល់ស្លាកអាជីវកម្មចំនួន២៨៨ ពុំទាន់ត្រូវបានប្រមូលពន្ធ។

ការខកខានក្នុងការប្រមូលពន្ធលើស្លាកយីហោរបស់រដ្ឋបាលសារពើពន្ធធ្វើឱ្យបាត់បង់ចំណូលថវិកា។ ដើម្បីកៀរគរចំណូលថវិកា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគួរណែនាំអគ្គនាយដ្ឋានពន្ធដារឱ្យចាត់វិធានការបន្ថែមទៀត ដើម្បីប្រមូលពន្ធឱ្យអស់លទ្ធភាព។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានឯកភាពតាមអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិ និងធ្វើការកែលម្អការប្រមូលពន្ធនេះ។

៣.១.៣.គុណភាពសវនកម្មតាមប្រភេទពន្ធ

ការធ្វើសវនកម្មលើអ្នកជាប់ពន្ធ គឺដើម្បីប្រមូលចំណូលពន្ធដែលអ្នកជាប់ពន្ធធ្វេសប្រហែសដោយអចេតនា ឬចេតនា។ ជាងនេះទៀត ដើម្បីឱ្យការធ្វើសវនកម្មនេះមានប្រសិទ្ធភាព រដ្ឋបាលសារពើពន្ធត្រូវជ្រើសរើសអ្នកជាប់ពន្ធដែលមានហានិភ័យខ្ពស់មកធ្វើសវនកម្មឱ្យបានទាន់ពេលវេលា។ តាមការធ្វើសវនកម្មលើការធ្វើសវនកម្មតាមប្រភេទពន្ធរបស់សាខាពន្ធដារខណ្ឌ និងសាខាពន្ធដារខេត្តមួយចំនួន ក្នុងឆ្នាំ២០១២ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថាអង្គភាពពន្ធដារខាងលើបានជ្រើសរើសអ្នកជាប់ពន្ធមកធ្វើសវនកម្មតាមប្រភេទពន្ធ ដោយមិនបានកំណត់ហានិភ័យរបស់អ្នកជាប់ពន្ធនីមួយៗដែលត្រូវចុះធ្វើសវនកម្មទេ។ ម៉្យាងវិញទៀត តាមការធ្វើសវនកម្មលើលិខិតប្រកាសពន្ធប្រចាំខែនៅតាមបណ្តាសាខាពន្ធដារខាងលើ បានបង្ហាញឱ្យឃើញថា ក្រុមហ៊ុនមួយចំនួនប្រកាសចំណូលទាប មិនប្រកាសចំណាយទិញទំនិញ ប៉ុន្តែប្រកាសផលពីការលក់ទំនិញ ប្រកាសចំណាយលើសេវា ប៉ុន្តែមិនប្រកាសពន្ធកាត់ទុកទូទៅតាមអត្រា១៥% ជាដើម ដោយមិនត្រូវបានដាក់បញ្ចូលក្នុងកម្មវិធីសវនកម្មទេ។

ការរៀបចំកម្មវិធីសវនកម្ម ដោយមិនបានកំណត់ហានិភ័យរបស់អ្នកជាប់ពន្ធធ្វើឱ្យការធ្វើសវនកម្មអាចមិនទទួលបាននូវលទ្ធផលល្អ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានឯកភាពតាមអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិ។ ជាងនេះទៀត ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងណែនាំឲ្យអគ្គនាយកដ្ឋានពន្ធដារឲ្យពង្រឹងធ្វើការកែលម្អការកំណត់ហានិភ័យសម្រាប់ការធ្វើសវនកម្មចំពោះខេត្ត-ខណ្ឌដែលមានការពាក់ព័ន្ធទាំងនេះ។

៣.១.៤.ការអនុវត្តតួនាទីរបស់សាខាគយ និងរដ្ឋាករាជធានីភ្នំពេញ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញប្រកាសស្តីពីការបង្កើត និងដាក់ឲ្យដំណើរការនូវសាខាគយ និងរដ្ឋាករាជធានីភ្នំពេញ ដោយតម្រូវឲ្យសាខាគយ និងរដ្ឋាករាជធានីភ្នំពេញមានភារកិច្ច ដូចជា៖ ស្រាវជ្រាវ ទប់ស្កាត់ និងបង្ក្រាបរាល់បទល្មើសគយនានាលើទំនិញនាំចូលដោយគេចពន្ធតាមគ្រប់រូបភាពដែលកំពុងសន្និធិ ចរាចរ ចែកចាយ ឬកំពុងប្រើប្រាស់តាម

បណ្តាអាជីវកម្មដ្ឋាន ភណ្ឌាគារទំនិញ មូលដ្ឋានផលិតកម្ម ឬលំនៅដ្ឋាននានា និងចុះស្រង់និងកសាងបញ្ជីជំរឿនស្ថិតិ អាជីវកម្មដ្ឋានលក់ដុំ លក់រាយភណ្ឌាគារសន្និធិទំនិញនានា ដែលស្ថិតក្រោមប្រព័ន្ធគ្រប់គ្រងពិសេសរួមមាន យានយន្តគ្រប់ប្រភេទ ផលិតផលតេលសិលាភេសជ្ជៈ ព្រមទាំងទំនិញរសើបមួយចំនួនទៀត។ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា សាខាគយ និងរដ្ឋាករាជធានីភ្នំពេញ នៅមិនទាន់បានបំពេញភារកិច្ចពេញលេញនៅឡើយ ដោយមិនទាន់បានកសាងបញ្ជីជំរឿនស្ថិតិអាជីវកម្មលក់ដុំ លក់រាយភណ្ឌាគារសន្និធិទំនិញនៅក្នុងភូមិសាសាស្ត្រគ្រប់គ្រងរបស់រាជធានីភ្នំពេញនៅឡើយ។

ការគ្រប់គ្រងអាជីវកម្មដ្ឋានដែលមិនមានបញ្ជីជំរឿនស្ថិតិច្បាស់លាស់ ជាហេតុធ្វើឲ្យមានទំនិញគេចពន្ធគយនៅតែនាំចូល និងការទប់ស្កាត់រាល់ការប្រព្រឹត្តបទល្មើសច្បាប់គយមិនមានប្រសិទ្ធភាព។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គួរពង្រឹងការងារជំរឿនបញ្ជីស្ថិតិអាជីវកម្មទាំងអស់ឲ្យបានពេញលេញ និងទាន់ពេលវេលា។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានទទួលស្គាល់នូវភាពទន់ខ្សោយមួយចំនួនរបស់សាខាគយ និងរដ្ឋាករាជធានីភ្នំពេញក្នុងការអនុវត្តតួនាទីរបស់ខ្លួន ជាពិសេសការយឺតយ៉ាវក្នុងការធ្វើបច្ចុប្បន្នភាពបញ្ជីជំរឿនស្ថិតិអាជីវកម្មលក់ដំ លក់រាយភណ្ឌាគារ សន្និធិទំនិញនានា។ ជាការពិត សាខានេះមិនមែនមិនបានកសាងបញ្ជីជំរឿនស្ថិតិទាំងនោះទេ គ្រាន់តែពុំបានធ្វើបច្ចុប្បន្នភាពបញ្ជីនេះឲ្យបានទៀងទាត់ប៉ុណ្ណោះ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងណែនាំឲ្យសាខាគយ និងរដ្ឋាករាជធានីភ្នំពេញពង្រឹងការអនុវត្តការងាររបស់ខ្លួនឲ្យបានពេញលេញតាមបទប្បញ្ញត្តិជាធរមាន ជាពិសេសការធ្វើបច្ចុប្បន្នភាពបញ្ជីជំរឿនស្ថិតិអាជីវកម្មដ្ឋានធុរជនឲ្យបានទៀងទាត់តាមកាលកំណត់ ដើម្បីផ្សារភ្ជាប់ទិន្នន័យសូចនាករហានិភ័យសម្រាប់ជាមូលដ្ឋានរបស់ប្រព័ន្ធគ្រប់គ្រងភាពជឿជាក់លើធុរជន (Trader Credibility Management System- TCMS) ជាធរមាន។

៣.១.៥. ការកំណត់ទម្ងន់សម្រាប់គិតពន្ធលើទំនិញល្មើស

អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាបានចេញលិខិតស្តីពីការដាក់ឲ្យអនុវត្តតារាងតម្លៃចម្លងការសម្រាប់ជាមូលដ្ឋានពិចារណាលើមុខទំនិញមួយចំនួន ដែលចូលមកបំពេញបែបបទគយនាំចូលចាប់ពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០១២ ដោយបញ្ជាក់ថា ចំពោះតម្លៃគិតពន្ធគយលើទំនិញល្មើសច្បាប់គយគ្រប់ប្រភេទត្រូវកំណត់ដោយបូកបន្ថែម៥០% (ហាសិបភាគរយ) លើតម្លៃគិតពន្ធគយ និងចំពោះឯកតាគិតតម្លៃគិតពន្ធគយជាទម្ងន់ត្រូវផ្អែកលើមូលដ្ឋានទម្ងន់ទាំងសំបកវេចខ្ចប់ (Gross Weight)។ តាមការធ្វើតេស្តលើកំណត់ហេតុល្មើសច្បាប់គយនៅសាខាគយ និងរដ្ឋាករាជធានីភ្នំពេញ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ការកំណត់តម្លៃគិតពន្ធគយលើទំនិញល្មើសសំលៀកបំពាក់ថ្មី សាខាគយ និងរដ្ឋាករាជធានីភ្នំពេញបានធ្វើការកំណត់តម្លៃគិតពន្ធតែលើទម្ងន់សុទ្ធប៉ុណ្ណោះ ដោយមិនបានយកទម្ងន់ទាំងសំបកវេចខ្ចប់មកកំណត់ប្រាក់ពន្ធទេ។

ការកំណត់តម្លៃគិតពន្ធដែលមិនសមស្របតាមទម្ងន់ជាក់ស្តែងនេះ ជាហេតុធ្វើឲ្យមានការបាត់ចំណូលប្រាក់ពន្ធ និងប្រាក់ពិន័យផ្សេងៗ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគួរណែនាំអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាឲ្យពិនិត្យឡើងវិញចំពោះការកំណត់ទម្ងន់គិតពន្ធលើទំនិញនាំចូលដែលល្មើសច្បាប់ ដើម្បីសមស្របតាមបទប្បញ្ញត្តិដែលមាន។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសូមឯកភាព និងបញ្ជាក់ថា ករណីនេះអាចជាការធ្វេសប្រហែសមួយ ដោយមន្ត្រីគយមានសមត្ថកិច្ចបានយកតួលេខបរិមាណទំនិញល្មើសចេញតែពីកំណត់ហេតុល្មើសច្បាប់គយ ហើយខកខានពុំបានផ្ទៀងផ្ទាត់ជាមួយឯកសារភ្ជាប់ផ្សេងទៀត។ ក្រសួងនឹងណែនាំឲ្យអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាផ្តល់ការណែនាំដល់សាខាគយ និងរដ្ឋាករភ្នំពេញមានអប្បមាទខ្ពស់បន្ថែមទៀតក្នុងការងារ និងតម្រូវឲ្យជម្រះបញ្ហីទូទាត់កាតព្វកិច្ចពន្ធអាករឡើងវិញសម្រាប់ករណីខាងលើនេះ តាមបទប្បញ្ញត្តិជាធរមាន។

៣.១.៦.ការបោះពុម្ពវិញ្ញាបនបត្រពិនិត្យសុខភាពកម្មករនិយោជិកខ្មែរនិងបរទេស

ប្រកាសលេខ១១៩១ សហវ.ប្រក.ចមព ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីអាករប័ណ្ណការងារ សៀវភៅការងារ និងកម្រៃសេវាពិនិត្យសុខភាពបានកំណត់ថា ការបោះពុម្ពប័ណ្ណការងារ សៀវភៅការងារ វិញ្ញាបនបត្រពិនិត្យសុខភាព និងប័ណ្ណចំណូលត្រូវស្ថិតក្រោមការគ្រប់គ្រងត្រួតពិនិត្យរបស់គណៈកម្មការអន្តរក្រសួងរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ"។ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ការចំណាយលើការបោះពុម្ពវិញ្ញាបនបត្រពិនិត្យសុខភាពកម្មករនិយោជិកខ្មែរ និងបរទេស ក្នុងឆ្នាំ២០១២ មានទឹកប្រាក់ចំនួន២៧.០៩៤.៤០០រៀល និង៣.២៦៧,៥០ដុល្លារអាមេរិក ពុំមានឯកសារបញ្ជាក់អំពីការចូលរួមត្រួតពិនិត្យរបស់គណៈកម្មការអន្តរក្រសួងទេ។

អាស្រ័យហេតុនេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ គួរអនុវត្តឱ្យបានត្រឹមត្រូវស្របតាមខ្លឹមសារនៃប្រកាសខាងលើនេះ។

ឆ្លើយតបចំពោះការលើកឡើងខាងលើ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានបញ្ជាក់ថា នឹងខិតខំអនុវត្តឱ្យបានត្រឹមត្រូវស្របតាមគោលការណ៍ដែលនៅមានសុពលភាព។

៣.១.៧.ការតាមដានថវិកាចំណាយរដ្ឋទេយ្យបុរេប្រទានតាមកម្មវិធី

សារាចរណែនាំលេខ០១៤សហវ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ស្តីពីការចំណាយតាមនីតិវិធីរដ្ឋទេយ្យបុរេប្រទានបានកំណត់ថា រដ្ឋទេយ្យបុរេប្រទានត្រូវកាន់បញ្ជីគណនេយ្យទ្វេភាគក្នុងលក្ខខណ្ឌច្រើន ឬតិចធ្វើឱ្យសាមញ្ញទៅតាមទំហំ។ បញ្ជីរបស់រដ្ឋទេយ្យករបុរេប្រទានត្រូវមាន៖ បញ្ជីបេឡា ទិន្នានុប្បវត្តិសរុប និងសៀវភៅធំ..."។ តាមការធ្វើសវនកម្មលើការចំណាយប្រាក់រដ្ឋទេយ្យបុរេប្រទានតាមកម្មវិធីនៅនាយកដ្ឋានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋនិងប្រកាសអន្តរក្រសួងស្តីពីការតែងតាំងរដ្ឋទេយ្យករតាមកម្មវិធី អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា រដ្ឋទេយ្យករតាមកម្មវិធីមិនបានរៀបចំបញ្ជីបេឡា ទិន្នានុប្បវត្តិ ឬសៀវភៅធំទេ គឺមានតែតារាងតាមដានថវិកាបើកផ្តល់តាមកម្មវិធីពីរតនាគារជាតិប៉ុណ្ណោះ។

អាស្រ័យហេតុនេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ គួរធ្វើការណែនាំដល់អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អនុវត្តឱ្យបានត្រឹមត្រូវតាមខ្លឹមសារនៃសារាចរណែនាំខាងលើនេះ។

ឆ្លើយតបចំពោះការលើកឡើងខាងលើ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានបញ្ជាក់ថានឹងរៀបចំបញ្ជីបេឡា និងឯកសារផ្សេងៗស្របតាមការណែនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

៣.១.៨.ការប្រមូលផ្តុំកិច្ចលទ្ធកម្មដាក់ជាកញ្ចប់លទ្ធកម្ម

សារាចរណែនាំលេខ០០៦ សហវ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០៧ ស្តីពីការរៀបចំផែនការលទ្ធកម្មឆ្នាំ២០០៨ និងឆ្នាំបន្តបន្ទាប់បានកំណត់ឱ្យគ្រប់អង្គភាពលទ្ធកម្មត្រូវប្រមូលផ្តុំតម្រូវការដែលស្ថិតក្នុងប្រភេទដូចគ្នា ហើយមានលក្ខណៈបច្ចេកទេសដូចគ្នាស្រដៀងគ្នា ឬបម្រើការតែមួយបញ្ចូលក្នុងក្រុមតែមួយដែលហៅថាឡូត៍លទ្ធកម្ម ដើម្បីធ្វើកិច្ចលទ្ធកម្មតែមួយលើក។ ឡូត៍លទ្ធកម្មមួយចំនួនដែលមានភាពប្រហាក់ប្រហែល ឬស្រដៀងគ្នាត្រូវបញ្ចូលគ្នាជាក្រុមធំមួយហៅថា កញ្ចប់លទ្ធកម្ម សម្រាប់ធ្វើកិច្ចលទ្ធកម្មតែមួយលើក។ តាមការធ្វើសវនកម្មលើរបាយការណ៍ចំណាយលទ្ធកម្ម និងឯកសារកិច្ចសន្យាលទ្ធកម្មក្នុងឆ្នាំ២០១២ ដែលប្រើប្រាស់ថវិកាតាមកម្មវិធី និងមិនមែនកម្មវិធី អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈពុំទាន់បានប្រមូលផ្តុំជាកញ្ចប់លទ្ធកម្មដែលស្ថិតនៅក្នុងប្រភេទដូចគ្នា ឬស្រដៀងគ្នា ឬបម្រើការតែមួយដើម្បីធ្វើលទ្ធកម្មតែមួយលើកទេមានដូចជាការងារចាក់ខ្សាច់ និងការងារជួសជុលជាដើម។

ដើម្បីឱ្យការងារលទ្ធកម្មមានតម្លាភាព និងអាចជឿជាក់បាន ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈគួរអនុវត្តឱ្យបានត្រឹមត្រូវតាមខ្លឹមសារនៃសារាចរណែនាំខាងលើ។

ឆ្លើយតបចំពោះការលើកឡើងខាងលើ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានបញ្ជាក់ថា ក្រសួងនឹងខិតខំកែតម្រូវតាមអនុសាសន៍នេះ។

៣.១.៩.ការបើកឯកសារនិងប្រគល់កិច្ចសន្យាលទ្ធកម្ម

អនុក្រឹត្យលេខ១០៥ អនក្រ.បក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៦ ស្តីពីលទ្ធកម្មសាធារណៈ បានកំណត់ថាគ្រប់សំណើដេញថ្លៃ និងសំណើជ្រើសរើសទីប្រឹក្សាទាំងអស់ (ទាំងបច្ចេកទេស និងហិរញ្ញវត្ថុ) ត្រូវតែរៀបចំបើកជាសាធារណៈ ហើយកំណត់ហេតុត្រូវផ្តល់ឱ្យក្រុមហ៊ុន និងបុគ្គលដែលបានចូលរួមទាំងអស់។ កំណត់ហេតុត្រូវបិទប្រកាសលើបញ្ជរព័ត៌មាននៅស្ថាប័នអនុវត្តលទ្ធកម្មដែលសាធារណៈជនទូទៅអាចមើលឃើញ និងអាចថតចម្លង ក៏អាចផ្តល់ឱ្យសាធារណៈជនដែលបានដាក់ពាក្យស្នើសុំ។ តាមការធ្វើសវនកម្មលើរបាយការណ៍អនុវត្តលទ្ធកម្មថវិកាតាមកម្មវិធី និងមិនមែនកម្មវិធីរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈក្នុងឆ្នាំ២០១២ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា មានកិច្ចសន្យាអនុវត្តលទ្ធកម្មសរុបចំនួន៣០ មានទឹកប្រាក់សរុប៣៣.៣៥០.២៦២.០០០រៀល ក្នុងនោះមាន០៦ កិច្ចសន្យាដែលមានទឹកប្រាក់សរុបចំនួន១.៣១៩.៥៨១.២២០រៀល ផ្គត់ផ្គង់សម្ភារការិយាល័យ និងចាក់

ខ្សាច់នៅវិទ្យាស្ថានបណ្តុះបណ្តាលបច្ចេកវិទ្យា បានបើកឯកសារដេញថ្លៃ និងប្រគល់កិច្ចសន្យា នៅពេលវេលាតែមួយ (ម៉ោង និងថ្ងៃ ខែ ឆ្នាំ)។

អាស្រ័យហេតុនេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈគួរអនុវត្តឱ្យបានត្រឹមត្រូវតាមខ្លឹមសារនៃអនុក្រឹត្យខាងលើ និងគោលការណែនាំស្តីពីលទ្ធកម្មសាធារណៈ។

ឆ្លើយតបចំពោះការលើកឡើងខាងលើ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានបញ្ជាក់ថា ក្រសួងនឹងខិតខំអនុវត្តឱ្យបានត្រឹមត្រូវស្របតាមខ្លឹមសារនៃគោលការណ៍ណែនាំស្តីពីលទ្ធកម្មសាធារណៈ។

៣.១.១០.ការប្រមូលចំណូលពីអាជ្ញាបណ្ណប្រេកង់ស៍

យោងតារាងស្ថិតិអតិថិជន ដែលបានទទួលការអនុញ្ញាតឲ្យប្រើប្រាស់ប្រេកង់ស៍គ្រប់ប្រភេទក្នុងឆ្នាំ២០១២ និងតារាងចំណូលអាជ្ញាបណ្ណប្រេកង់ស៍ឆ្នាំ២០១២ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍បានចេញអាជ្ញាបណ្ណជូនអតិថិជនចំនួន ៤ ៧៥៦ រីឯចំណូលដែលទទួលបានមានចំនួន ១ ៨២១ អាជ្ញាបណ្ណ ស្មើនឹង ១ ៣៧០ ៦៧១ដុល្លារ និង ២៥ ០៤៧ ៤៥០ រៀល។

អាស្រ័យហេតុនេះ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ គួរអនុវត្តការប្រមូលចំណូលពីអាជ្ញាបណ្ណប្រេកង់ស៍ឲ្យបានសមស្របតាមចំនួនអាជ្ញាបណ្ណក្នុងការិយបរិច្ឆេទនីមួយៗ។

ឆ្លើយតបនឹងការលើកឡើងខាងលើ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍បានបំភ្លឺពីមូលហេតុមួយចំនួន ដូចជាក្រសួងអនុវត្តតាមនីតិវិធីរដ្ឋបាលគឺចេញអាជ្ញាបណ្ណរួចហើយទើបធ្វើលិខិតអញ្ជើញសាមីប្រើប្រាស់មកបង់កម្រៃអាជ្ញាបណ្ណនៅនាយកដ្ឋានផែនការ និងហិរញ្ញវត្ថុ និងក្រសួងបានបន្តអាជ្ញាបណ្ណជូនទោះបីពុំមានការស្នើសុំឈប់ពីសាមីប្រើប្រាស់ដោយដឹងថាប្រេកង់ស៍ទាំងនោះនៅកំពុងប្រើប្រាស់ ប៉ុន្តែក្រសួងនឹងធ្វើការកែប្រែបញ្ហានេះ។

៣.១.១១.ការចេញសារណាការទារចំណូលលើផ្នែក Regulator fee ពីក្រុមហ៊ុន

ប្រកាសលេខ២៣២សហវបទ ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការកំណត់ថ្លៃសេវាទូរស័ព្ទចល័តនិងអចល័ត និងថ្លៃតភ្ជាប់បណ្តាញក្នុងផ្នែកទី១ ប្រការ៦ ចំណុចខ បានចែងថាការទូទាត់ត្រូវធ្វើឡើងដោយមានការឯកភាពរវាងគូភាគីទាំងអស់យ៉ាងយូរបំផុតក្នុងរយៈពេល ៣ខែម្តង។ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា គិតមកទល់ខែកញ្ញា ឆ្នាំ២០១៣ ក្រសួងមានភាពយឺតយ៉ាវក្នុងការចេញសារណាការទារចំណូលលើផ្នែក Regulator Fee ពីក្រុមហ៊ុនចំនួន១០ ចាប់ពីរយៈពេល០១ខែដល់០៦ខែ។

អាស្រ័យហេតុនេះ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ គួរអនុវត្តនីតិវិធីនៃការប្រមូលចំណូលពីផ្នែក Regulator Fee ឲ្យបានត្រឹមត្រូវតាមខ្លឹមសារនៃប្រកាសខាងលើ ។

ជាការឆ្លើយតប ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងអង្គភាពជំនាញទទួលស្គាល់នូវចំណុចខ្វះចន្លោះដែលបានលើកឡើងលើការអនុវត្តចេញសារណាការទារចំណូលលើផ្នែក Regulator Fee ពីក្រុមហ៊ុនតាមខ្លឹមសារនៃប្រកាសលេខ២៣២ សហវបទ ចុះថ្ងៃទី០៧

ខែធ្នូ ឆ្នាំ២០០៩។ ទោះជាការអនុវត្តនៅមានកង្វះខាត នាយកដ្ឋានជំនាញនឹងខិតខំទៅតាមលទ្ធភាពដែលអាចធ្វើទៅបាន ដើម្បីកែលម្អស្របតាមបទប្បញ្ញត្តិជាធរមាន ហើយបច្ចុប្បន្ននេះ ក្រសួងក៏បានបង្កើតនូវមជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យ (Data Management Center) រួចហើយ ដើម្បីគ្រប់គ្រង និងដោះស្រាយបញ្ហានេះ។

៣.១.១២.ការចុះកិច្ចសន្យាស្តីពីការបង់ចំណូលដុលជាមួយក្រុមហ៊ុនចម្រុះ

យោងបទបញ្ជាលេខ០៤បប ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ត្រង់ចំណុចទី៧ ចែងថាចំពោះកិច្ចសន្យាដែលតម្រូវឲ្យបង់ជារបបមៅការ ឬភាគរយលើចំណូលដុល (Revenue Sharing) ត្រូវជំរុញឲ្យក្រុមហ៊ុនដែលជាប់កិច្ចសន្យាទាំងនោះបង់ចំណូល១ខែម្តង។ កាលបរិច្ឆេទនៃការបង់ចំណូលមិនឲ្យលើសពីថ្ងៃទី២០នៃខែបន្ទាប់ឡើយ ចំពោះកិច្ចសន្យាណាដែលពុំបានចែងពីកាលបរិច្ឆេទនៃការបង់ចំណូល១ខែម្តង ត្រូវធ្វើការកែសម្រួលកិច្ចសន្យានេះឡើងវិញ។ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា គិតមកទល់ខែកញ្ញា ឆ្នាំ២០១៣ ក្រសួងបានចេញអាជ្ញាបណ្ណឲ្យក្រុមហ៊ុនចំនួន៧២ ប្រើប្រាស់ចាប់ពីឆ្នាំ២០០៧ ដល់ខែមិថុនា ឆ្នាំ២០១៣ ប៉ុន្តែក្រសួងនៅបន្តរក្សាតាមខ្លឹមសារនៃការបង់ចំណូល០៣ខែម្តង ដោយពុំទាន់បានកែប្រែតាមខ្លឹមសារនៃបទបញ្ជានៅឡើយ។

អាស្រ័យហេតុនេះ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍គួរខិតខំអនុវត្តឲ្យបានត្រឹមត្រូវតាមខ្លឹមសារនៃបទបញ្ជាលេខ០៤ខាងលើឲ្យបានសមស្រប។

ឆ្លើយតបនឹងការលើកឡើងខាងលើ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍បានបំភ្លឺថា ដោយសារមានអាជ្ញាបណ្ណមួយចំនួនត្រូវបានក្រសួងចេញមុនបទបញ្ជាលេខ០០៤បប ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាល ទើបការចេញអាជ្ញាបណ្ណបន្តបន្ទាប់ទៀត ក្រសួងបានរក្សាខ្លឹមសារតាមអាជ្ញាបណ្ណដែលចេញមុនៗ ដើម្បីរក្សាលំនាំ និងទម្រង់ដើមតែមួយជៀសវាងមិនមានតម្លាភាព។ ក្រសួងនឹងធ្វើការកែប្រែឲ្យមានការឯកភាពគ្នានូវខ្លឹមសារ និងកាតព្វកិច្ចនៅពេលដែលច្បាប់ទូរគមនាគមន៍ត្រូវបានអនុម័ត ។

៣.២.ការគ្រប់គ្រងថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

៣.២.១.ការស្វែងរកមុខសញ្ញាចំណូល

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញសារាចរណែនាំស្តីពីការអនុវត្តថវិកាខេត្ត ក្រុង ជារៀងរាល់ឆ្នាំ មានជាអាទិ៍សារាចរលេខ ០១៧ សហវ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៦ សារាចរលេខ០០៩ សហវ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០០៧ សារាចរលេខ០០១ សហវ ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០០៩ និងសារាចរលេខ ០០៥ សហវ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១០ បានតម្រូវឱ្យខេត្តយកចិត្តទុកដាក់ស្រាវជ្រាវកំណត់មុខសញ្ញាចំណូល ដែលត្រូវប្រមូលបង់ចូលរតនាគារឱ្យអស់ មិនត្រូវទុកចំណូលខ្លះនៅដោយឡែកសម្រាប់ចំណាយប្រចាំឆ្នាំឡើយ។

តាមការធ្វើសវនកម្មលើការប្រមូលចំណូលមិនមែនសារពើពន្ធឆ្នាំ២០១២ ដែលស្ថិតក្រោមសមត្ថកិច្ចរបស់មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តមួយចំនួនឃើញថា មានផ្សារមួយចំនួនសមត្ថកិច្ចជំនាញមិនទាន់បានរៀបចំសំណុំបែបបទប្រមូលចំណូលពីការជួលតូប រាន ស្តង់ នៅឡើយ។

ដោយសារការខកខានមិនបានរៀបចំសំណុំបែបបទប្រមូលចំណូលពីការជួលតូប រាន ស្តង់នៅក្នុងទីផ្សារទាំងនេះ បានធ្វើឱ្យបាត់ចំណូលថវិកាខេត្ត។ អាស្រ័យហេតុនេះ សាលាខេត្តគួរណែនាំមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអង្គភាពពាក់ព័ន្ធឱ្យខិតខំស្រាវជ្រាវមុខសញ្ញាចំណូលនិងប្រមូលចំណូលទាំងនោះបង់ចូលថវិកាខេត្តតាមសារាចរណែនាំខាងលើ។

ឆ្លើយតបនឹងការលើកឡើងនេះ សាលាខេត្តទាំងនេះបានបញ្ជាក់ថា អាជ្ញាធរខេត្តនឹងបង្កើតគណៈកម្មការដើម្បីចុះស្រង់ស្ថិតិតូប រាន ស្តង់ និងកំណត់តម្លៃពីការជួលតូប រាន ស្តង់ទាំងនោះ។ ប៉ុន្តែមានការលំបាកដៃរក្នុងការកំណត់តម្លៃជួល ព្រោះតូប រាន ស្តង់ក្នុងផ្សារមួយចំនួន គឺអាជីវករជាអ្នកសាងសង់ដោយខ្លួនឯង។

៣.២.២.ការប្រមូលចំណូលសោហ៊ុយសេវាលើការបិទការដ្ឋានសំណង់

ប្រកាសអន្តរក្រសួងលេខ០៣៣សហវ.ប្រក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០០៦ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ស្តីពីសោហ៊ុយលើសេវាសំណង់ ត្រង់ប្រការ១ និងប្រការ២បានបញ្ជាក់ថា ការសុំលិខិតអនុញ្ញាតសាងសង់ លិខិតបើកការដ្ឋានលិខិតបិទការដ្ឋាន ឬវិញ្ញាបនប័ត្របញ្ជាក់ភាពត្រឹមត្រូវលើការចុះបញ្ជីប្រកបអាជីវកម្មសាងសង់ និងសិក្ខាគម្រោងប្លង់មានផ្ទៃក្រឡាកម្រាលសំណង់ចាប់ពី១០០ម៉ែត្រការ៉េដល់៣.០០០ម៉ែត្រការ៉េ គឺស្ថិតនៅក្រោមសមត្ថកិច្ចរបស់ខេត្ត ក្នុងនោះមាន៖

– លិខិតអនុញ្ញាតសាងសង់ត្រូវបង់សោហ៊ុយសេវាចាប់ពី៤០.០០០រៀល ដល់ ៣៤០.០០០ រៀល

– លិខិតអនុញ្ញាតសាងសង់ពង្រីកបន្ថែម រុះរើ ជួសជុល ត្រូវបង់សោហ៊ុយសេវាចាប់ពី២០.០០០រៀល ដល់ ៣០០.០០០រៀល

– លិខិតអនុញ្ញាតបើកការដ្ឋានត្រូវបង់សោហ៊ុយសេវាចាប់ពី៥.០០០ រៀល ដល់ ១១០.០០០ រៀល

– លិខិតបិទការដ្ឋាន ឬវិញ្ញាបនប័ត្របញ្ជាក់ភាពត្រឹមត្រូវ ត្រូវបង់សោហ៊ុយសេវា ចាប់ពី១០.០០០ រៀល ដល់១១៥.០០០ រៀល។

តាមការធ្វើសវនកម្មលើរបាយការណ៍ចំណូលសោហ៊ុយសេវាសំណង់ឆ្នាំ២០១២ នៅមន្ទីរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី និងខេត្តមួយចំនួន ឃើញថាមន្ទីរដែនដីខេត្តបានចេញលិខិតអនុញ្ញាតសាងសង់ និងបើកការដ្ឋានសំណង់សរុបចំនួន៣៦ និងមន្ទីរនៃរាជធានីចំនួន៥០៩ ប៉ុន្តែពុំបានត្រួតពិនិត្យបច្ចេកទេស និងបិទការដ្ឋានឱ្យបានគ្រប់ចំនួនឡើយ ។

ដោយសារការខកខានមិនបានត្រួតពិនិត្យ និងបិទការដ្ឋានសំណង់ អាចនាំឱ្យសំណង់សង់មិនបានត្រឹមត្រូវតាមប្លង់ និងគុណភាពបច្ចេកទេស។ ម៉្យាងទៀតនាំឱ្យបាត់ចំណូលសោហ៊ុយសេវាសំណង់លើការបិទការដ្ឋាន។ ដូចនេះ សាលាខេត្ត និងសាលារាជធានីគួរណែនាំមន្ទីរនេះឱ្យអនុវត្តតាមប្រកាសអន្តរក្រសួងខាងលើ។

ឆ្លើយតបចំពោះការលើកឡើងនេះ សាលាខេត្ត និងសាលារាជធានីបានបញ្ជាក់ថា អាជ្ញាធរនឹងណែនាំឱ្យមន្ទីរនេះរៀបចំបង្កើតគណៈកម្មការចម្រុះដោយមានមន្ត្រីជំនាញ និងអាជ្ញាធរមូលដ្ឋានចូលរួម ដើម្បីជំរុញដល់ការប្រមូលចំណូលពីការបិទការដ្ឋានសំណង់ដែលបានសាងសង់ គ្មានលិខិតអនុញ្ញាតសាងសង់ ដើម្បីប្រមូលចំណូលពីប្រភពចំណូលខាងលើនេះ។

ផ្អែកតាមការប្តេជ្ញាចិត្តរបស់សាលាខេត្ត និងសាលារាជធានី អាជ្ញាធរសវនកម្មជាតិសង្ឃឹមថា ការងារគ្រប់គ្រងសំណង់ និងការប្រមូលចំណូលសោហ៊ុយសេវាសំណង់នឹងទទួលបានលទ្ធផលល្អប្រសើរនាពេលខាងមុខ។

៣.៣.ការអនុវត្តគម្រោងវិនិយោគ

៣.៣.១.ការបង្កើតគណៈកម្មការទទួលខុសត្រូវក្នុងការត្រួតពិនិត្យតាមដានលើការអនុវត្តកិច្ចសន្យាវិនិយោគ

ដើម្បីឱ្យការវិនិយោគប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល គ្រប់កិច្ចសន្យាវិនិយោគទាំងអស់បានតម្រូវឱ្យមានការត្រួតពិនិត្យតាមដានការអនុវត្តកិច្ចសន្យាវិនិយោគតាំងពីការចាប់ផ្តើមរហូតដល់ការបញ្ចប់ជាស្ថាពរ។ ក្នុងឆ្នាំ២០១២កន្លងមក តាមការធ្វើសវនកម្មលើកិច្ចសន្យាវិនិយោគចំនួនពីរ រវាងសាលារាជធានីភ្នំពេញជាមួយក្រុមហ៊ុនលើការវិនិយោគផ្លូវចោមចៅ-ស្ទឹងមានជ័យ និងការវិនិយោគមជ្ឈមណ្ឌលពាណិជ្ជកម្មផ្សារអូឡាំពិកឃើញថា ការត្រួតពិនិត្យនិងតាមដានកិច្ចសន្យានៅខ្វះចន្លោះដោយសារសាលារាជធានីភ្នំពេញពុំទាន់បានបង្កើតគណៈកម្មការទទួលខុសត្រូវក្នុងការត្រួតពិនិត្យតាមដានលើការអនុវត្តកិច្ចសន្យាវិនិយោគនៅឡើយទេ។

អាស្រ័យហេតុនេះ ដើម្បីឱ្យការអនុវត្តតាមលក្ខខណ្ឌ និងខ ចែងនៃកិច្ចសន្យាវិនិយោគប្រកបដោយប្រសិទ្ធភាព សាលារាជធានីភ្នំពេញគួរតែបង្កើតគណៈកម្មការទទួលខុសត្រូវក្នុងការត្រួតពិនិត្យតាមដានលើការអនុវត្តកិច្ចសន្យាវិនិយោគខាងលើ។

ឆ្លើយតបចំពោះការលើកឡើងខាងលើនេះ សាលារាជធានីភ្នំពេញបានបំភ្លឺថា កាលពីអាណត្តិនៃកិច្ចសន្យាចាស់ពុំទាន់បានបង្កើតគណៈកម្មការទទួលខុសត្រូវក្នុងការត្រួតពិនិត្យតាមដានលើការថែទាំ និងជួសជុលផ្លូវមែន ប៉ុន្តែចាប់ពីពេលនេះតទៅ ពិសេសក្នុងការអនុវត្តកិច្ចសន្យាថ្មី សាលារាធានីភ្នំពេញនឹងរៀបចំបង្កើតគណៈកម្មការទទួលខុសត្រូវក្នុងការត្រួតពិនិត្យតាមដានលើការថែទាំ និងជួសជុលផ្លូវឱ្យបានត្រឹមត្រូវ។

៣.៣.២.ការយកតម្លៃភាស៊ីគ្រប់ប្រភេទ

ក្នុងការអនុវត្ត និងគ្រប់គ្រងតម្លៃនៃការប្រមូលភាស៊ីគ្រប់ប្រភេទឱ្យមានលក្ខណៈល្អ ប្រសើរ មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានីភ្នំពេញបានតម្រូវឱ្យការប្រមូលភាស៊ីគ្រប់ប្រភេទ ត្រូវយកទៅតាមតារាងកំណត់តម្លៃនៃសៀវភៅបន្ទុក និងប្រើប្រាស់ប័ណ្ណភាស៊ីច្បាប់ដើមដែលចេញដោយមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានីភ្នំពេញ ហាមយកប័ណ្ណនេះទៅថតចម្លង កោសកែតម្លៃ និងបោះពុម្ពដោយគ្មានការអនុញ្ញាត។ កន្លងមកការងារនេះពុំទាន់អនុវត្តបានពេញលេញនៅឡើយទេ។ ជាក់ស្តែងក្នុងឆ្នាំ២០១២ ផ្អែកតាមការធ្វើសវនកម្មលើកិច្ចសន្យាវិនិយោគមជ្ឈមណ្ឌលពាណិជ្ជកម្មផ្សារអូឡាំពិក ក្រុមហ៊ុនបានយកតម្លៃភាស៊ីលើសពីការកំណត់តម្លៃក្នុងសៀវភៅបន្ទុក និងពុំមានប័ណ្ណភាស៊ីចេញឱ្យម្ចាស់យានយន្តទេសម្រាប់ការផ្ទើរថយន្តក្រៅបរិវេណមជ្ឈមណ្ឌលផ្សារអូឡាំពិក។

អាស្រ័យហេតុនេះ ដើម្បីឱ្យការអនុវត្ត និងគ្រប់គ្រងតម្លៃភាស៊ីមានប្រសិទ្ធភាព សាលារាជធានីភ្នំពេញគួរណែនាំឱ្យក្រុមហ៊ុនវិនិយោគផ្សារទាំងអស់អនុវត្តទៅតាមសៀវភៅបន្ទុក និងចេញប័ណ្ណភាស៊ីឱ្យបានត្រឹមត្រូវ។

ឆ្លើយតបចំពោះការលើកឡើងខាងលើនេះ សាលារាជធានីភ្នំពេញបានបំភ្លឺថា បានធ្វើការណែនាំអ្នកមៅការប្រមូលភាស៊ីឱ្យអនុវត្តឱ្យបានត្រឹមត្រូវតាមកិច្ចសន្យា សៀវភៅបន្ទុក និងបានចេញលិខិតចុងក្រោយលេខ៦៨ ឆត.ផវិ.ម ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១៤ គឺបញ្ឈប់ភ្នាក់ងារប្រមូលចំណូលភាស៊ីលើទីតាំងតែម្តង ក្នុងករណីមានការប្រមូលភាស៊ីចំណូលលើសសៀវភៅបន្ទុក និងចាប់ពីពេលនេះតទៅ សាលារាធានីភ្នំពេញនឹងចាត់វិធានការយ៉ាងតឹងរ៉ឹងបំផុតចំពោះករណីនេះ បើនៅតែអនុវត្តខុសសៀវភៅបន្ទុកទៀតនឹងលុបទីតាំងនោះតែម្តង។

៤. ការពិនិត្យទៅលើវឌ្ឍនភាពនៃការអនុវត្តអនុសាសន៍សវនកម្ម

ផ្អែកតាមលទ្ធផលនៃការធ្វើសវនកម្មសម្រាប់ការិយបរិច្ឆេទ២០១២ និងនាពេលកន្លងមក អាជ្ញាធរសវនកម្មជាតិកត់សម្គាល់ឃើញថា រាល់ចំណុចខ្វះខាត និងអនុសាសន៍សវនកម្មទាំងឡាយដែលអាជ្ញាធរសវនកម្មជាតិបានលើកឡើងក្នុងនោះចំណុចមួយចំនួនត្រូវបានក្រសួងស្ថាប័ន រដ្ឋបាលរាជធានីខេត្ត រដ្ឋបាលមូលដ្ឋាន និងអង្គភាពពាក់ព័ន្ធនានាខិតខំអនុវត្តកែលម្អគួរឱ្យកត់សម្គាល់ និងកោតសសើរ រីឯចំណុចមួយចំនួនទៀតគួរខិតខំធ្វើឱ្យប្រសើរឡើង មានជាអាទិ៍ ៖

៤.១. ការប្រើប្រាស់ ឬការចេញវិក្កយបត្រឲ្យទៅអតិថិជន៖ តាមច្បាប់ស្តីពីសារពើពន្ធគឺតម្រូវឲ្យមានការប្រើប្រាស់ ឬចេញវិក្កយបត្រចំពោះរាល់កិច្ចការជំនួញរវាងអ្នកជាប់ពន្ធ និងបុគ្គលដទៃទៀត។ ចំពោះវិក្កយបត្រអាករលើតម្លៃបន្ថែម គឺត្រូវមានចុះលេខរៀងត្រឹមត្រូវឲ្យទៅអ្នកទិញ និងត្រូវមានចុះនិទ្ទេសដូចជា៖ ឈ្មោះ និងលេខចុះបញ្ជីរបស់អ្នកលក់ កាលបរិច្ឆេទចេញវិក្កយបត្រ ឈ្មោះអ្នកទិញ ឬនិយោជិក ឬភ្នាក់ងារអ្នកទិញ បរិមាណ សេចក្តីបរិយាយ និងថ្លៃលក់ទំនិញ ឬសេវា។ ជាងនេះទៅទៀត វិក្កយបត្រ សម្រាប់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសត្រូវមាន

អាសយដ្ឋាន លេខអត្តសញ្ញាណកម្ម "អតប" លេខវិក្កយបត្រ ថ្ងៃខែឆ្នាំចេញវិក្កយបត្រ រាយមុខទំនិញ ឬសេវា បរិមាណ ថ្លៃឯកតា ថ្លៃសរុប គោត្តនាម និងនាមអ្នកចេញវិក្កយបត្រ...។ តាមការធ្វើតេស្តលើការប្រើប្រាស់វិក្កយបត្ររបស់សណ្ឋាគារដែលស្ថិតនៅក្នុងវិស័យនៃសកម្មភាពផ្នែកសណ្ឋាគារ ផ្ទះសំណាក់ និងភោជនីយដ្ឋាន អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា សណ្ឋាគារមួយចំនួនបានប្រើប្រាស់ ឬចេញវិក្កយបត្រឲ្យទៅអតិថិជនដោយពុំទាន់មានលក្ខណៈត្រឹមត្រូវនៅឡើយ ពោលគឺវិក្កយបត្រគ្មានលេខអត្តសញ្ញាណកម្ម "អតប" គ្មានលេខវិក្កយបត្រ គ្មានគោត្តនាម និងនាមអ្នកចេញវិក្កយបត្រ...។ ការប្រើប្រាស់ ឬចេញវិក្កយបត្រដោយមិនបានបំពេញព័ត៌មានច្បាស់លាស់ អាចពុំបញ្ជាក់បានពីភាពត្រឹមត្រូវ និងអាចជះឥទ្ធិពលដល់ការប្រមូលពន្ធ និងការធ្វើសវនកម្ម។

៤.២. របាយការណ៍សវនកម្មរបស់សវនករឯករាជ្យ៖ ចំពោះសហគ្រាសវិនិយោគទាំងឡាយដែលបានធ្វើសកម្មភាពអាជីវកម្ម គឺមានកាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុប្រចាំការិយបរិច្ឆេទនីមួយៗរបស់ខ្លួនជូនសវនករឯករាជ្យសម្រាប់ធ្វើសវនកម្មស្របទៅតាមច្បាប់ដែលបានកំណត់ ចំពោះសហគ្រាសដែលមានលក្ខណៈវិនិច្ឆ័យពីរក្នុងចំណោមលក្ខណៈវិនិច្ឆ័យបីគឺ (១) ផលរបរប្រចាំឆ្នាំសហគ្រាសមានចំនួនចាប់ពីបីពាន់លានរៀលឡើងទៅ (២)ទ្រព្យសកម្មសរុបមានតម្លៃចាប់ពីពីរពាន់លានរៀលឡើងទៅ (៣) និយោជិកបម្រើការងារមានចំនួនចាប់ពីមួយរយនាក់ឡើងទៅ និងរាល់គម្រោងវិនិយោគដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ហើយបានចុះឈ្មោះនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ពោលគឺសហគ្រាសដែលមានលក្ខណៈវិនិច្ឆ័យដូចនេះ ត្រូវមានរបាយការណ៍សវនកម្មនៃសវនករឯករាជ្យ។ ក្នុងឆ្នាំ២០១២ នាយកដ្ឋានសវនកម្មសហគ្រាសនៃអគ្គនាយកដ្ឋានពន្ធដារបានចុះធ្វើសវនកម្មលើសហគ្រាសដែលមានលក្ខណៈវិនិច្ឆ័យត្រូវមានរបាយការណ៍សវនកម្មនៃសវនករឯករាជ្យ ក្នុងនោះមួយចំនួនពុំឃើញមានរបាយការណ៍សវនកម្មនៃសវនករឯករាជ្យឡើយ។ ប្រការដែលសហគ្រាសមានលក្ខណៈវិនិច្ឆ័យគ្រប់គ្រាន់ តែមិនមានរបាយការណ៍សវនកម្មនៃសវនករឯករាជ្យ អាចបង្កឲ្យមានការលំបាកដល់ការអនុវត្តមុខងារសវនកម្មរបស់សវនកពន្ធដារ ហើយរបាយការណ៍ហិរញ្ញវត្ថុរបស់សហគ្រាសអាចខ្វះនូវភាពជឿជាក់។

៤.៣.ការប្រមូលពន្ធអចលនទ្រព្យ៖ ជាគោលការណ៍ ការបង់ពន្ធលើអចលនទ្រព្យ គឺអនុញ្ញាតឲ្យម្ចាស់អចលនទ្រព្យអាចមកបង់ប្រាក់ពន្ធលើអចលនទ្រព្យដោយផ្ទាល់នៅបេឡាសាខាពន្ធដារខេត្ត-ខណ្ឌដែលម្ចាស់អចលនទ្រព្យនោះស្ថិតនៅ ឬអាចបង់តាមប្រព័ន្ធធនាគារតាមការណែនាំរបស់សាខាពន្ធដារខេត្ត-ខណ្ឌ..” តាមស្ថិតិពន្ធអចលទ្រព្យរបស់អគ្គនាយកដ្ឋានពន្ធដារ។ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ការប្រមូលចំណូលលើពន្ធអចលនទ្រព្យឆ្នាំ២០១២ បានចំនួន ១២៨.៣២៣ មូលដ្ឋានជាប់ពន្ធ ស្មើនឹងប្រាក់ពន្ធប្រមាណចំនួន៦៧.០៣៧ លានរៀល។ តាមការធ្វើតេស្តនៅសាខាពន្ធដារតាមខណ្ឌនៃរាជធានីភ្នំពេញ និងសាខាពន្ធដារខេត្តចំនួន០៩ ក្នុងចំណោម២៤សាខាពន្ធដារ រាជធានី ខេត្ត អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្នុងឆ្នាំ២០១២ អ្នកជាប់ពន្ធមួយចំនួនមិនបានផ្តល់ព័ត៌មានអំពីអចលនទ្រព្យ មិនមកចុះបញ្ជីពន្ធអចលនទ្រព្យ

មិនមកប្រកាសបង់ពន្ធលើអចលនទ្រព្យ ហើយក្នុងនោះមានអ្នកជាប់ពន្ធមួយចំនួនទៀត ដែលបានមកប្រកាសបង់ពន្ធអចលនទ្រព្យឆ្នាំ២០១១រួចម្តងហើយ ប៉ុន្តែក្នុងឆ្នាំ២០១២ មិនបានមកប្រកាសបង់ពន្ធជាបន្ត។

៤.៤.ការគ្រប់គ្រងអ្នកជាប់ពន្ធតាមរបបមៅការ៖ ច្បាប់ស្តីពីសារពើពន្ធ និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីសារពើពន្ធ បានកំណត់ថា អ្នកជាប់ពន្ធតាមរបបមៅការមានកាតព្វកិច្ចដាក់លិខិតប្រកាសសារពើពន្ធជូនរដ្ឋបាលសារពើពន្ធជារៀងរាល់ឆ្នាំយ៉ាងយឺតបំផុតនៅថ្ងៃទី៣១ខែតុលា។ ចំនួនទឹកប្រាក់មៅការត្រូវកំណត់ដោយរដ្ឋបាលសារពើពន្ធ បន្ទាប់ពីបានពិនិត្យ និងពិភាក្សាជាមួយអ្នកជាប់ពន្ធ ឬអ្នកតំណាងនិងប្រាក់ចំណេញទៅតាមប្រភេទ និងតាមមុខរបរអាជីវកម្ម ដែលត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ការកម្រិតពន្ធលើប្រាក់ចំណេញមៅការត្រូវកំណត់ជាស្ថិរវន្តសម្រាប់រយៈពេលមួយកំណត់ ៣ខែ ៦ខែ ឬមួយឆ្នាំ អ្នកជាប់ពន្ធលើប្រាក់ចំណេញរបបមៅការត្រូវបង់ពន្ធនេះជារៀងរាល់ខែតាមពេលវេលាដែលកំណត់ដោយរដ្ឋបាលសារពើពន្ធ។ តាមការធ្វើសវនកម្ម អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា មន្ត្រីពន្ធដារនៃសាខាពន្ធដារខណ្ឌនិងខេត្តនានា បានចុះប្រមូលប្រាក់ពន្ធដល់អាជីវកម្មដ្ឋានដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួនផ្ទាល់ ពោលគឺម្ចាស់អាជីវកម្មដ្ឋាន ពុំបានទៅបង់ពន្ធនៅរដ្ឋបាលសារពើពន្ធនោះទេ។

៤.៥.ការទៅបំពេញកាតព្វកិច្ចចុះបញ្ជីសារពើពន្ធសហគ្រាស៖ តាមច្បាប់ស្តីពីសារពើពន្ធ សហគ្រាសដែលចុះបញ្ជីនៅក្រសួងពាណិជ្ជកម្មរួចរាល់ ត្រូវរួសរាន់ទៅចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធក្នុងអំឡុង១៥ថ្ងៃ។ ក្នុងករណីមិនបានទៅចុះបញ្ជីទេនោះ រដ្ឋបាលសារពើពន្ធអាចធ្វើការចុះបញ្ជីចាប់តាំងពីពេលដែលសហគ្រាសត្រូវទៅចុះបញ្ជី ហើយការចុះបញ្ជីបែបនេះសហគ្រាសត្រូវមានការទទួលខុសត្រូវចំពោះប្រាក់អាករទាំងអស់ចាប់តាំងពីកាលបរិច្ឆេទដែលបានកំណត់។ ប៉ុន្តែតាមការធ្វើតេស្តសហគ្រាសចំនួន២៨២ដែលបានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្មក្នុងឆ្នាំ២០១២ ឃើញថា មានសហគ្រាសចំនួន ១៨៨ បានមកបំពេញកាតព្វកិច្ចចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធ រីឯចំនួនសហគ្រាសនៅសល់ពីនេះពុំមានប្រភពបញ្ជាក់ច្បាស់លាស់ឡើយ។

៤.៦.ការប្រកាសពន្ធរបស់សហគ្រាស៖ ការដាក់លិខិតប្រកាសពន្ធអាករប្រចាំខែ ប្រចាំឆ្នាំនៅរដ្ឋបាលសារពើពន្ធត្រូវធ្វើឡើងដោយភាពត្រឹមត្រូវ និងច្បាស់លាស់ ហើយបណ្ណាធិការសហគ្រាសជាអ្នកទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់ ប្រសិនបើព័ត៌មានណាមួយមានការក្លែងបន្លំ។ តាមការធ្វើសវនកម្ម អាជ្ញាធរសវនកម្មសង្កេតឃើញថា មានសហគ្រាសមួយចំនួនបានដាក់លិខិតប្រកាសពន្ធមកអគ្គនាយកដ្ឋានពន្ធដារដោយប្រកាសតម្លៃលក់ផលិតផលតេលសិលាទាបជាងតម្លៃទីផ្សារ (ប្រេងឥន្ធនៈ)។

៤.៧.ការបញ្ចូលមូលដ្ឋានអាជីវកម្មទៅក្នុងរបបស្វ័យប្រកាស៖ សហគ្រាសទាំងឡាយដែលបានទទួលធ្វើ ឬផ្គត់ផ្គង់អ្វីមួយ ឬក៏ច្រើនជូនអង្គការសាធារណៈ ហើយដែលមានចំនួនទឹកប្រាក់សរុបទាំងអស់លើសពីមួយរយម៉ែប្រាំលានរៀល សហគ្រាសទាំងនោះត្រូវស្ថិតក្នុងក្របខណ្ឌនៃការកំណត់ពន្ធតាមរបបពិតប្រាកដ ឬរបបស្វ័យប្រកាសដោយមិនគិតពីផលរបរប្រចាំឆ្នាំផងទេ។ តាម

ការធ្វើសវនកម្មនៅសាខាពន្ធដារខណ្ឌ និងសាខាពន្ធដារខេត្តមួយចំនួនឃើញថា មានមូលដ្ឋានអាជីវកម្មដែលស្ថិតក្នុងរបបមៅការមួយចំនួនបានធ្វើការផ្គត់ផ្គង់ទំនិញ និងសេវាទៅឲ្យអង្គភាពរដ្ឋដោយផលរបរប្រចាំឆ្នាំសរុបមានចំនួនលើសពីមួយរយម្ភៃប្រាំលានរៀល ប៉ុន្តែមិនត្រូវបានអង្គភាពពន្ធដារចាត់បញ្ចូលទៅក្នុងរបបស្វ័យប្រកាសឡើយ។

៥.៨.ភាពសហការរវាងអគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា៖
ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានបង្កើតក្រុមការងារចម្រុះរវាងអគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ដោយបានតម្រូវឱ្យអង្គភាពទាំងពីរនេះធ្វើកិច្ចសហការគ្នាផ្លាស់ប្តូរពិត៌មាន ទិន្នន័យ បញ្ជីឈ្មោះសហគ្រាស និងសកម្មភាពអាជីវកម្មដើម្បីងាយស្រួលក្នុងការគ្រប់គ្រង និងបង្ក្រាបអំពើរត់ពន្ធផ្សេងៗ។ ប៉ុន្តែ តាមការធ្វើសវនកម្ម អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយដ្ឋានគយ និងរដ្ឋាករកម្ពុជា បានធ្វើកិច្ចសហការផ្លាស់ប្តូរព័ត៌មាន ទិន្នន័យ បញ្ជីឈ្មោះអ្នកជាប់ពន្ធនិងសកម្មភាពអាជីវកម្មរបស់សហគ្រាស ប៉ុន្តែកិច្ចសហការរវាងអង្គភាពទាំងពីរនេះនៅពុំទាន់បានជិតស្និទ្ធនៅឡើយ ដោយហេតុថា ការផ្លាស់ប្តូរព័ត៌មាន ទិន្នន័យក្រុមហ៊ុន នៅមានការកម្រិតកំណត់ ហើយមានការយឺតយ៉ាវ។

៥.៩.ការគ្រប់គ្រងអ្នកជាប់ពន្ធតាមរបបមៅការ៖ តាមច្បាប់ស្តីពីសារពើពន្ធ និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីសារពើពន្ធ បានកំណត់ថា អ្នកជាប់ពន្ធតាមរបបមៅការមានកាតព្វកិច្ចដាក់លិខិតប្រកាសសារពើពន្ធជូនរដ្ឋបាលសារពើពន្ធជារៀងរាល់ឆ្នាំយ៉ាងយឺតបំផុតនៅថ្ងៃទី៣១ ខែតុលា។ ចំនួនទឹកប្រាក់មៅការត្រូវកំណត់ដោយរដ្ឋបាលសារពើពន្ធ បន្ទាប់ពីបានពិនិត្យ និងពិភាក្សាជាមួយអ្នកជាប់ពន្ធ ឬអ្នកតំណាងនិងប្រាក់ចំណេញទៅតាមប្រភេទ និងតាមមុខរបរអាជីវកម្មដែលត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ការកម្រិតពន្ធលើប្រាក់ចំណេញមៅការត្រូវកំណត់ជាស្ថិរវន្តសម្រាប់រយៈពេលមួយកំណត់៣ខែ ៦ខែ ឬ១ឆ្នាំ អ្នកជាប់ពន្ធលើប្រាក់ចំណេញរបបមៅការត្រូវបង់ពន្ធនេះជារៀងរាល់ខែតាមពេលវេលាដែលកំណត់ដោយរដ្ឋបាលសារពើពន្ធ។ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា មន្ត្រីពន្ធដារភាគច្រើននៃសាខាពន្ធដារខណ្ឌ និងខេត្តនានាបានចុះប្រមូលប្រាក់ពន្ធដល់អាជីវកម្មដ្ឋាន ដែលស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់ខ្លួន ពោលគឺម្ចាស់អាជីវកម្មដ្ឋានពុំបានទៅបង់ពន្ធនៅកន្លែងដែលរដ្ឋបាលសារពើពន្ធបានកំណត់នោះទេ។

៥.១០.ការប្រមូលពន្ធតាមរបបមៅការ៖ ការប្រមូលពន្ធនៃរបបនេះអាចប្រព្រឹត្តទៅបានពេញលេញលុះត្រាតែអាជីវកម្មដ្ឋានទាំងឡាយត្រូវបានចុះបញ្ជីអនុម័តពន្ធត្រឹមត្រូវ។ រដ្ឋបាលសារពើពន្ធមានតួនាទីជំរឿនអ្នកជាប់ពន្ធ កំណត់ពន្ធ និងដាក់បញ្ចូលអាជីវកម្មក្នុងបញ្ជីអនុម័តពន្ធ។ ប៉ុន្តែតាមការធ្វើសវនកម្មឃើញថា អាជីវកម្មដ្ឋានមួយចំនួនមិនទាន់ត្រូវបានបញ្ចូលទៅក្នុងបញ្ជីអនុម័តពន្ធនៅឡើយ។

៥.១១. ការជម្រះផ្ទេរចំណូលចូលថវិកា៖ ច្បាប់ និងគោលការណ៍ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុចំណូលត្រូវកត់ត្រាចូលទាំងស្រុង មិនត្រូវទូទាត់ជាមួយចំណាយឡើយ។ ចំណូលថវិកាទាំងអស់ទោះបីស្ថិតក្នុងប្រភេទចំណូលណាក៏ដោយ អាណាប័កគ្មានសិទ្ធិដកយកទៅចំណាយ ឬមួយ

ពន្យារការបង់ចូលថវិកាជាតិដើម្បីទុកប្រើប្រាស់ជាផលប្រយោជន៍ណាមួយបានឡើយ។ ប៉ុន្តែ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាមានទឹកប្រាក់ចំនួន៣.៥៤៥.៩២៧.៤០៧រៀល និងអគ្គនាយកដ្ឋានពន្ធដារមាន ទឹកប្រាក់ចំនួន៤.៤៣៩.៩៩១.១៧១រៀល មិនទាន់ត្រូវបានផ្ទេរចូលថវិកាជាតិនៅឡើយ។

៤.១២. ការតាមដានលើការប្រើប្រាស់ទំនិញនាំចូលក្រោមរបបអនុគ្រោះពន្ធ៖ នាយកដ្ឋានរបប គយនៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា មានតួនាទីភារកិច្ចធ្វើការតាមដានសម្ភារ បរិក្ខារ និងទំនិញគ្រប់ប្រភេទដែលទទួលបានការអនុគ្រោះពន្ធនានាតាមទិសដៅដែលបានកំណត់ និង ត្រួតពិនិត្យលើការប្រើប្រាស់ដោយរួមទាំងការចុះទៅបំពេញភារកិច្ចតាមដាន និងឃ្លាំមើលជា អចិន្ត្រៃយ៍ ឬលក្ខណៈម្តងម្កាលតាមបណ្តាអាជីវកម្មដ្ឋានឬពាណិជ្ជកម្មនានាស្របតាមនីតិវិធី ច្បាប់ជាធរមាន។ តាមការធ្វើសវនកម្ម អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ពុំមានឯកសារ ឬរបាយការណ៍ ឬកំណត់ហេតុដែលអាចបញ្ជាក់ថា នាយកដ្ឋាននេះបានធ្វើការត្រួតពិនិត្យតាម ដានលើការប្រើប្រាស់សម្ភារបរិក្ខារ និងវត្ថុធាតុដើមទាំងឡាយដែលបាននាំចូលដោយពន្ធ និង អាករជាបន្ទុករបស់រដ្ឋនោះឡើយតាមរយៈការពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយន្តការសវនកម្ម ក្រោយពេលបញ្ចេញទំនិញវិញ។

៤.១៣.ការដោះស្រាយទំនិញគ្មានការទាមទារ៖ ប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពី ការគ្រប់គ្រងទំនិញគ្មានការទាមទារបានបញ្ជាក់ថា ក្រោយរយៈពេលហុកសិបថ្ងៃ(៦០ថ្ងៃ) គិតពី ថ្ងៃចេញប្រវេសន៍សាធារណៈ ម្ចាស់ទំនិញត្រូវធ្វើការទាមទារទំនិញរបស់ខ្លួន។ ប្រសិនបើហួស រយៈពេលនេះ ទំនិញត្រូវដាក់លក់ដោយការដាក់ឱ្យដេញថ្លៃជាសាធារណៈស្របតាមបញ្ញត្តិនៃ ប្រកាសនេះ។ ប៉ុន្តែតាមការធ្វើសវនកម្ម អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា រហូតមកដល់ ឆ្នាំ២០១២នេះ កុងតឺន័រទំនិញចម្រុះនៅសាខាគយ និងរដ្ឋាករផែអន្តរជាតិក្រុងព្រះសីហនុដែល សល់តាំងពីឆ្នាំ១៩៩៩ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២ មានចំនួន១៥៦កុងតឺន័រ (ទំនិញរក្សាទុកក្នុង ឃ្លាំង) នៅពុំទាន់ត្រូវបានធ្វើការដោះស្រាយនៅឡើយ។

៤.១៤.ការរក្សាទុកប្រាក់លក់ទំនិញរឹបអូស និងទំនិញបាតឃ្លាំង៖ ប្រកាសរបស់ក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការគ្រប់គ្រងលើទំនិញនាំចូលបានបញ្ជាក់ថា ផលពីការលក់ទំនិញ ដែលនៅសល់ក្រោយពីការចំណាយផ្សេងៗ ត្រូវដាក់ក្នុងបេឡានៃនិក្ខិត្តភ័ណ្ឌនិងបញ្ជើត្រូវទុក រយៈពេល២ឆ្នាំដើម្បីរង់ចាំម្ចាស់ទំនិញឬសិទ្ធិលាភទាំងឡាយ ហើយជុតរយៈពេលវេលានេះត្រូវ បានជាគុណប្រយោជន៍ដល់ថវិការដ្ឋ។ តាមការធ្វើសវនកម្ម អាជ្ញាធរសវនកម្មជាតិសង្កេតឃើញ ថា ផលពីការលក់ទំនិញរឹបអូស និងលក់ទំនិញបាតឃ្លាំងផ្សេងៗជុតរយៈពេល២ឆ្នាំមួយចំនួន ត្រូវបានអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាដកយកទៅប្រើប្រាស់ក្នុងការផ្តល់រង្វាន់លើកទឹក ចិត្ត និងចំណាយផ្សេងៗ។ គិតមកដល់ចុងឆ្នាំ២០១២នេះ ទឹកប្រាក់ដែលនៅសល់ ហើយដែលពុំ ពាក់ព័ន្ធនឹងម្ចាស់ទំនិញ ឬសិទ្ធិលាភទាំងឡាយនោះមានចំនួន៩៩៥ ៧៧៥ ៥៧៣រៀល និង ប្រាក់ដុល្លារអាមេរិកមានចំនួន ៥៧៩ ៥៥៣ ដុល្លារអាមេរិក អគ្គនាយកដ្ឋានគយ និងរដ្ឋាករ កម្ពុជា នៅតែមិនទាន់បានបង់ចូលថវិការដ្ឋនៅឡើយ។

៤.១៥. ការរក្សាទុកសាច់ប្រាក់ក្នុងបេឡាលើសកម្រិតកំណត់៖ សាវាចរណែនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការកែលម្អនីតិវិធីអនុវត្តថវិកា បានកំណត់ចំនួនទឹកប្រាក់ចំណូលរបស់រដ្ឋ ដែលភ្នាក់ងារ ឬអង្គភាពប្រតិបត្តិនីមួយៗអាចរក្សាទុកនៅក្នុងបេឡារបស់ខ្លួនត្រឹមចំនួនពី២លានរៀល ទៅ៥លានរៀលប៉ុណ្ណោះ។ តាមការធ្វើសវនកម្ម អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អង្គភាពប្រតិបត្តិចំណូលមួយចំនួន នៅតែរក្សាទុកសាច់ប្រាក់ចំណូលក្នុងបេឡារបស់ខ្លួនលើសកម្រិតកំណត់ ព្រមទាំងរក្សាទុកយូរថ្ងៃទើបបង់ចូលថវិកា។

៤.១៦.ការកត់ត្រាចំណូលថវិការដ្ឋ៖ តាមបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ ការកត់ត្រាចំណូលថវិកាត្រូវផ្អែកលើមូលដ្ឋានសលាកប័ត្រ ឬដីកាចំណូលរបស់អាណាប័កក្រសួង ស្ថាប័ន រាជធានី ខេត្ត ដែលបានរៀបចំបញ្ជូនទៅឲ្យអគ្គនាយកដ្ឋានរតនាគារជាតិ ដើម្បីធ្វើការផ្ទៀងផ្ទាត់។ ប៉ុន្តែតាមការធ្វើសវនកម្មឃើញថា ចំណូលមួយចំនួនមិនត្រូវបានកត់ត្រាដោយផ្អែកលើមូលដ្ឋានសលាកប័ត្រ ឬដីកាចំណូលរបស់អាណាប័កនោះទេ គឺត្រូវបានអគ្គនាយកដ្ឋានរតនាគារជាតិកត់ត្រាផ្អែកលើប្រកាសឥណទាន ឬបង្កាន់ដៃបង់ប្រាក់ពីធនាគារជាតិប៉ុណ្ណោះ។

៤.១៧.ការផ្តល់អាជ្ញាប័ណ្ណអាជីវកម្មទទួលបញ្ចាំនិងទិញ-លក់ទ្រព្យបញ្ចាំ៖ ប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការផ្តល់អាជ្ញាប័ណ្ណអាជីវកម្មទទួលបញ្ចាំ និងទិញលក់ទ្រព្យបញ្ចាំ និងអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទានរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានបញ្ជាក់ថាក្រសួងនឹងផ្តល់អាជ្ញាប័ណ្ណជូនដល់អាជីវករទាំងឡាយណាដែលបានបំពេញលក្ខខណ្ឌដូចជា៖ មានកម្រិតវប្បធម៌ចាប់ពីថ្នាក់បរិញ្ញាប័ត្រ ឬប្រហាក់ប្រហែលផ្នែកសេដ្ឋកិច្ច ឬពាណិជ្ជកម្ម ឬនីតិសាស្ត្រ វិញ្ញាបនប័ត្រផ្សេងៗទៀតដែលទាក់ទងនឹងអាជីវកម្ម ឬមានបទពិសោធន៍ពាក់ព័ន្ធទៅនឹងការគ្រប់គ្រងផ្នែកអាជីវកម្ម ឬធ្លាប់បម្រើការងារផ្នែកនេះពីមុន។ ប៉ុន្តែតាមការធ្វើតេស្តលើឯកសារស្នើសុំអាជ្ញាប័ណ្ណរបស់អាជីវករមួយចំនួនក្នុងចំណោមឯកសារស្នើសុំអាជ្ញាប័ណ្ណចំនួន៥២ដែលត្រូវបានផ្តល់ឱ្យដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងឆ្នាំ២០១២ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ឯកសារស្នើសុំអាជ្ញាប័ណ្ណមួយចំនួន មិនបានភ្ជាប់មកជាមួយនូវឯកសារគ្រប់គ្រាន់តាមខ្លឹមសារនៃប្រកាសខាងលើនៅឡើយ។ ជាក់ស្តែង វិស័យនេះមានការរីកចំរើនពីមួយឆ្នាំទៅមួយឆ្នាំ។ ជាមួយនោះដែរ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក៏មានវិធានការគ្រប់គ្រងកាន់តែមានភាពល្អប្រសើរពីតំណាក់កាលមួយទៅតំណាក់កាលមួយទៀតផងដែរ តាមការកំណត់របស់រាជរដ្ឋាភិបាល ដើម្បីលើកកំពស់ និងអភិវឌ្ឍន៍វិស័យនេះប្រកបដោយទំនុកចិត្ត សុវត្ថិភាព និងការទទួលខុសត្រូវចំពោះមុខច្បាប់។

៤.១៨. ការទូទាត់ និងការកត់ត្រាចំណាយ៖ ជាគោលការណ៍ ការបញ្ជូនអាណត្តិបើកប្រាក់ទៅអគ្គនាយកដ្ឋានរតនាគារជាតិ ត្រូវបានកំណត់ឱសានវាទត្រឹមវេលាម៉ោង១៧ និង៣០នាទី នាថ្ងៃទី៣១ ខែធ្នូនៃឆ្នាំសារពើពន្ធ។ តាមការធ្វើសវនកម្មឃើញថា ការបញ្ជូនអាណត្តិបើកប្រាក់ទៅអគ្គនាយកដ្ឋានរតនាគារជាតិ ប្រព្រឹត្តទៅពុំទាន់មានភាពសមស្របនៅឡើយ ដោយអាណត្តិបើកប្រាក់មួយចំនួនដែលបានបោះផ្សាយរួចហើយពុំទាន់បានធ្វើការទូទាត់ និងកត់ត្រាចំណាយទាន់ពេលវេលា ហើយអាណត្តិបើកប្រាក់មួយចំនួនតែងបានបញ្ជូនទៅរតនាគារជាតិធ្វើការទូ

ទាត់នៅក្រោយថ្ងៃឱសានវាទបិទបញ្ជី ដែលបង្កឲ្យមានការកកស្ទះអាណត្តិបើកប្រាក់ និងលំបាកក្នុងការបូកសរុបបិទបញ្ជីប្រចាំឆ្នាំ។

៤.១៩.ការទូទាត់ប្រាក់បុរេប្រទាន៖ ប្រាក់បុរេប្រទានគឺជាប្រាក់បើកផ្តល់ឲ្យចំណាយមុនក្នុងករណីមានការចាំបាច់ ឬបន្ទាន់។ ជារៀងរាល់ឆ្នាំ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតែងបានចេញប្រកាសនិងសារាចរណែនាំដល់គ្រប់ក្រសួងស្ថាប័នឲ្យរួសរាន់ប្រមូលឯកសារដើម្បីស្នើសុំទូទាត់ប្រាក់បុរេប្រទានដែលបានចំណាយរួចហើយឲ្យបានមុនដំណាច់ឆ្នាំ ដោយគិតរួមទាំងចំណាយប្រាក់បុរេប្រទានជារូបិយប័ណ្ណអន្តរជាតិដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានផ្តល់ឲ្យតាមរយៈមូលប្បទានប័ត្រផងដែរ។ ក្នុងការអនុវត្តកន្លងមក ក្រសួងស្ថាប័នមួយចំនួនក្រោយពីការចំណាយរួចហើយ គឺពុំសូវបានរួតរះប្រមូលឯកសារដើម្បីស្នើសុំទូទាត់ឲ្យបានគ្រប់ចំនួន និងទាន់ពេលវេលានោះទេ។

៤.២០.ការដកចំណូលយកទៅចំណាយ៖ ច្បាប់ និងលិខិតបទដ្ឋាននានាស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុបានកំណត់ថា ចំណូលដែលប្រមូលបានត្រូវបង់ចូលថវិកាដោយមិនត្រូវបានអនុញ្ញាតឱ្យធ្វើការទូទាត់ជាមួយចំណាយណាមួយឡើយ។ ប៉ុន្តែអាជ្ញាធរសវនកម្មជាតិសង្កេតឃើញថាអង្គភាពប្រតិបត្តិចំណូលមួយចំនួនតែងតែដកចំណូលយកទៅប្រើប្រាស់ក្នុងរូបភាពដកវង្វាន់ និងចំណាយផ្សេងៗតាមបទប្បញ្ញត្តិពាក់ព័ន្ធនឹងការបែងចែកប្រាក់រង្វាន់ជាធរមាននៅមុនការបង់ចូលថវិការដ្ឋ។

៤.២១.ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ៖ អនុក្រឹត្យរបស់រាជរដ្ឋាភិបាល និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធលទ្ធកម្មសាធារណៈ បានបញ្ជាក់ថា ស្ថាប័នអនុវត្តលទ្ធកម្មត្រូវធ្វើរបាយការណ៍ស្តីពីការអនុវត្តកិច្ចលទ្ធកម្មប្រចាំខែទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឱ្យបានទៀងទាត់។ ប៉ុន្តែតាមការធ្វើសវនកម្ម អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រសួង ស្ថាប័ន សាលារាជធានី ខេត្ត និងសហគ្រាសសាធារណៈមួយចំនួនពុំបានធ្វើរបាយការណ៍ស្តីពីការអនុវត្តកិច្ចលទ្ធកម្មប្រចាំខែ ទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឱ្យបានទៀងទាត់ និងទាន់ពេលវេលានោះទេ។ សម្រាប់ការិយបរិច្ឆេទ២០១២នេះ មានក្រសួង ស្ថាប័នចំនួន១០ សាលាខេត្តចំនួន០៤ និងសហគ្រាសសាធារណៈចំនួន០៦ មិនបានធ្វើរបាយការណ៍ស្តីពីការអនុវត្តកិច្ចលទ្ធកម្មប្រចាំខែទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

៤.២២.ការធ្វើផែនការ និងការធ្វើផែនការលទ្ធកម្មប្រចាំឆ្នាំ៖ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យស្តីពីលទ្ធកម្មសាធារណៈដោយបានកំណត់ថា ស្ថាប័នអនុវត្តលទ្ធកម្មត្រូវធ្វើផែនការលទ្ធកម្មប្រចាំឆ្នាំរបស់ខ្លួនដាក់ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើម្បីពិនិត្យ និងអនុម័តនៅដើមឆ្នាំសារពើពន្ធនីមួយៗ។ សារាចរណែនាំស្តីពីការរៀបចំផែនការលទ្ធកម្មបានបញ្ជាក់ថា ប្រធានស្ថាប័នអនុវត្តលទ្ធកម្មត្រូវពិនិត្យ និងអនុម័តលើផែនការលទ្ធកម្មរបស់ខ្លួន រួចផ្ញើទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុយ៉ាងយឺតបំផុតត្រឹមសប្តាហ៍ទី១ ខែមករា នៃឆ្នាំសារពើពន្ធ។ តាមការធ្វើសវនកម្ម អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្នុងឆ្នាំ២០១២ ក្រសួងស្ថាប័ន រាជធានី ខេត្ត

និងសហគ្រាសសាធារណៈមួយចំនួនមានការយឺតយ៉ាវក្នុងការធ្វើផែនការលទ្ធកម្ម និងមិនបានផ្ញើផែនការលទ្ធកម្មប្រចាំឆ្នាំទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៅឡើយ។

៤.២៣.ការធ្វើបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ៖ សាខាចរណៃនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការកែសម្រួលធ្វើបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ បានតម្រូវឱ្យគ្រប់ក្រសួងស្ថាប័ន សាលារាជធានី ខេត្ត ធ្វើបញ្ជីសារពើភ័ណ្ឌលម្អិតសម្រាប់ឆ្នាំ២០០៤ឱ្យបានជាដាច់ខាតដើម្បីទុកជាឆ្នាំគោលសម្រាប់ការប្រៀបធៀបបញ្ជីសារពើភ័ណ្ឌឆ្នាំ២០០៥ និងនៅបណ្តាឆ្នាំចន្លោះ០៥ឆ្នាំ ស្តីពីការកើនឡើងនិងថយចុះនៃទ្រព្យសម្បត្តិរដ្ឋ។ ប៉ុន្តែតាមការធ្វើសវនកម្មអាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អង្គភាពប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋមួយចំនួនពុំបានអនុវត្តឱ្យបានពេញលេញតាមការតម្រូវខាងលើនេះទេ ដោយអង្គភាពមួយចំនួននៅតែមានការយឺតយ៉ាវក្នុងការធ្វើបញ្ជីសារពើភ័ណ្ឌឆ្នាំគោល ហើយខ្លះទៀតយឺតយ៉ាវក្នុងការរៀបចំតារាងប្រៀបធៀបការកើនឡើង និងថយចុះនៃទ្រព្យសម្បត្តិរដ្ឋ។

៤.២៤.ការធ្វើប័ណ្ណសម្គាល់កម្មសិទ្ធិលើទ្រព្យសម្បត្តិរដ្ឋ៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតែងតែបានចេញលិខិត និងសារចរណៃនាំផ្សេងៗណៃនាំឱ្យក្រសួងស្ថាប័ន រដ្ឋលេខាធិការដ្ឋាន និងសាលារាជធានី ខេត្ត ដែលជាអង្គភាពប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋត្រូវធ្វើប័ណ្ណសម្គាល់កម្មសិទ្ធិលើអចលនទ្រព្យ ដែលបាននិងកំពុងស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួនឱ្យបានគ្រប់ចំនួន និងឆាប់រហ័ស ជាប្រយោជន៍ដើម្បីធានាបាននូវភាពគង់វង្ស និងភាពស្របច្បាប់នៃទ្រព្យសម្បត្តិទាំងឡាយនោះ។ ប៉ុន្តែតាមការធ្វើសវនកម្ម អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា រហូតមកដល់ឆ្នាំ២០១២នេះ ទ្រព្យសម្បត្តិរដ្ឋមួយចំនួននៅតែពុំទាន់បានធ្វើប័ណ្ណសម្គាល់កម្មសិទ្ធិរួចរាល់នៅឡើយ។

៥. សេចក្តីសន្និដ្ឋាន

ផ្អែកតាមលទ្ធផលនៃការធ្វើសវនកម្មសម្រាប់ការិយបរិច្ឆេទ២០១២ឃើញថា រាជរដ្ឋាភិបាលសម្រេចបាននូវកំណើនសេដ្ឋកិច្ច៧,៣%លើសពីការព្យាករណ៍ដែលបានរំពឹងទុកចំនួន៦.៥% ព្រមទាំងកាត់បន្ថយបាននូវភាពក្រីក្រក្នុងអត្រាជាង១%ក្នុងមួយឆ្នាំដែលជាសមិទ្ធផលគួរជាទីមោទនៈ។

តាមរយៈការផ្តល់អនុសាសន៍កែលម្អនូវចំណុចខ្វះខាតនានា និងការចេញផ្សាយរបាយការណ៍សវនកម្មជាសាធារណៈជាបន្តបន្ទាប់មកនេះ អាជ្ញាធរសវនកម្មជាតិកត់សម្គាល់ឃើញថា អង្គភាពរងសវនកម្មបានខិតខំយកចិត្តទុកដាក់អនុវត្តកែលម្អគួរឲ្យកោតសរសើរ បើទោះបីនៅមានចំណុចមួយចំនួនមិនទាន់ត្រូវបានអនុវត្តឲ្យបានល្អប្រសើរនៅឡើយក៏ដោយ។ អាជ្ញាធរសវនកម្មជាតិសង្ឃឹមថា អង្គភាពរងសវនកម្មទាំងឡាយនឹងបន្តខិតខំអនុវត្តកែលម្អនូវរាល់កង្វះខាតទាំងនោះបានល្អប្រសើរ ទាន់ពេលវេលា និងជៀសវាងបាននូវការបន្តកើតមានកង្វះខាតដដែលៗជាបន្តទៅទៀត ដែលទាំងនេះគឺជាការចូលរួមចំណែកយ៉ាងសកម្ម ក្នុងការពង្រឹងអភិបាលកិច្ចល្អលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឲ្យបានកាន់តែរឹងមាំ និងប្រកបដោយប្រសិទ្ធភាព។

ទន្ទឹមនឹងនេះដែរ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានធ្វើរបាយការណ៍គោរពជូន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** លើលទ្ធផលការងារអធិការកិច្ចហិរញ្ញវត្ថុ ដែលបានរកឃើញនូវកំហុសឆ្គងរបស់ក្រសួង ស្ថាប័ន សហគ្រាសសាធារណៈ និងមន្ទីរជំនាញ និងបានធ្វើលិខិតចាត់វិធានការវិន័យរដ្ឋបាល ដើម្បីកែលម្អកំហុសឆ្គងលើការអនុវត្តនីតិវិធីហិរញ្ញវត្ថុ ដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានរកឃើញក្នុងការគ្រប់គ្រង ការប្រើប្រាស់ចំណូលចំណាយថវិការដ្ឋ ចំណូលមិនមែនសារពើពន្ធ កាតព្វកិច្ចបង់ចំណូលចូលថវិការដ្ឋ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋរបស់ក្រសួង ស្ថាប័ន សហគ្រាសសាធារណៈ និងមន្ទីរជំនាញ ដើម្បីអនុវត្តឱ្យមានប្រសិទ្ធភាពតាមនីតិវិធីហិរញ្ញវត្ថុ ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ ហើយបានចម្លងជូនក្រសួង ស្ថាប័នពាក់ព័ន្ធ ដូចជា៖ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច អង្គភាពប្រឆាំងអំពើពុករលួយ និងអាជ្ញាធរសវនកម្មជាតិ ដើម្បីចាត់ការបន្ត។

អាជ្ញាធរសវនកម្មជាតិមានជំនឿយ៉ាងមុតមាំថា ក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធនានា និងសាធារណជនទាំងឡាយ នឹងចូលរួមផ្តល់មតិស្ថាបនាលើរបាយការណ៍នេះ ព្រមទាំងផ្តល់ការលើកទឹកចិត្តចំពោះលទ្ធផលសម្រេចបាន ដែលជាកត្តាជំរុញឲ្យអាជ្ញាធរសវនកម្មជាតិបន្តខិតខំបង្កើនសមត្ថភាពការងាររបស់ខ្លួនប្រកបដោយវិជ្ជាជីវៈពេញលេញ សំដៅលើកកម្ពស់គុណភាពសវនកម្មឲ្យស្របតាមស្តង់ដារសវនកម្មក្នុងតំបន់ និងអន្តរជាតិ ដើម្បីចូលរួមចំណែកក្នុងការកសាង និងអភិវឌ្ឍប្រទេសជាតិប្រកបដោយចីរភាព។